BUDDHIST INSTITUTE

# បកិណ្ណកវិន័យ

មាន:

សំណួរ ចម្លើយ

ភ្នំពេញ

ព.ស. ២៥១៥ គ.ស. ១៩៧២

២៤១.
៧៩

JSRC KID FEBRUARY 1988

**ស្លាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្លាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសីុ-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្លាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

この本は、立正佼成会と曹洞宗ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

1988年 1 月14日

This book is specially printed as a cooperative project of Risshokoseikai and Sotoshu Volunteer's Association.

We pray that this Khmer reference would contribute to the friendship with Cambodian people and their cultural preservation.

ON JANUARY 14, 1988

សៀវភៅដែលលោកអ្នកកំពុងអាននេះ បោះពុម្ពដោយបានសហការរវាង-
សមាគម Risshokoseikai និង S.V.A. ជប៉ុន ។
ខ្ញុំសង្ឃឹមដោយស្មោះអស់ពីចិត្ត ថា សៀវភៅនេះជាកំណាប់នៃមិត្តភាពរវាង-
ប្រជាពលរដ្ឋខ្មែរ - ជប៉ុន ហើយនឹងរក្សានូវវប្បធម៌ខ្មែរ ឲ្យបានគង់វង្សតទៅ ។

ថ្ងៃទី ១៤ ខែ មករា ១៩៨៨

BUDDHIST INSTITUTE
១១៧/៥៥

# បកិណ្ណកវិន័យ

ដកស្រង់ពីវិន័យបិដក

សម្រាប់ជំនួយ

ផ្នែកពុទ្ធិកសិក្សា និង ធម្មវិន័យទូទៅ

ប្រមូលរៀបរៀងដោយ

អ៊ុង-សំអឿន ទិត-សែម

ការផ្សាយរបស់បណ្ណាគារ

លេខ ១៤៦ វិថីខេមរភូមិន្ទ ភ្នំពេញ

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ

ព.ស. ២៥១៥ គ.ស. ១៩៧២

# អារម្ភកថា

សៀវភៅថ្មី ដែលអស់លោកបានកាន់នេះមានឈ្មោះថា « **បកិណ្ណកវិន័យ** » សៀវភៅនេះខ្ញុំរៀបរៀងជាមួយនឹងមិត្រខ្ញុំមួយរូបឈ្មោះ **និត សែម** ដែលមានយោបល់ស្របគ្នាក្នុងការដោះស្រាយបញ្ហាក្នុងសៀវភៅនេះ ។ ជាជំនួយមួយយ៉ាងពិសេសសម្រាប់លោកអ្នកសិក្សាផ្នែកវិជ្ជានេះ ។ នៅក្នុងសៀវភៅនេះ ខ្ញុំបានប្រមែប្រមូលនូវបញ្ហាជាច្រើនដែលមាននៅក្នុងវិន័យបិដកខ្លះ កង្ខាវិតរណីខ្លះ នឹង បញ្ហាវិន័យដែលបានប្រឡងចូលពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ហើយ , ដែលខ្ញុំបានសិក្សាជាមួយលោក **ធូ សុទ្ធ** សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត យកមកធ្វើជាសំនួរ ហើយដោះស្រាយដើម្បីការងាយដល់អស់លោកដែលត្រូវការសិក្សាវិជ្ជានេះ ។ ម្យ៉ាងទៀតដោយខ្ញុំជាគ្រូបង្រៀនសាលាពុទ្ធិកបឋមសិក្សាវត្តព្រះពុទ្ធមានបុណ្យ (ភ្នំពេញ) មួយរូបផងនោះ ខ្ញុំត្រូវតែជួយដោះស្រាយការតានតឹងចំពោះសិស្សគាត់ខ្លះដែលពុំសូវយល់នូវវិជ្ជាផ្នែកវិន័យនេះ ។

ហេតុនេះហើយបានជាខ្ញុំ ពួតដៃជាមួយនិងមិត្តខ្ញុំ ដើម្បីធ្វើសំណួរនិងចម្លើយនៅក្នុងសៀវភៅនេះ ឲ្យបានគ្រាះក្លាយៗ សៀវភៅនេះ សមណសិស្សទាំងឡាយអាចសិក្សាបានគ្រប់ថ្នាក់ទាំងអស់ ។

នៅទីបំផុតនៃការម្ដុបខនេះយើងខ្ញុំទាំងពីររូបសូមផ្ញើសេចក្ដីទុកចិត្តទៅលើអស់លោកគ្រប់រូប សូមកុំមើលបំណាំក្រែងជាមានភ្លាំងភ្លាត់ត្រង់កន្លែងណាមួយ សូមជួយឲ្យយោបល់ដល់យើងខ្ញុំផង ពីព្រោះអ្នកធ្វើនីមួយ ៗ តែងតែមានកំហុសពុំខានឡើយ។

ដូច្នេះ បើមានការភ្លាំងភ្លាត់ ឬ ខ្វះខាតកន្លែងណា សូមលោកអ្នកសិក្សាមេត្តាឲ្យដំណឹងចំពោះយើងខ្ញុំ ។ ដើម្បីកែសៀវភៅឲ្យរឹតតែល្អឡើង ។

**អ៊ុច . សំអឿន និង និត·សែម**

# បរិច្ឆេទវិន័យ

សួ. ព្រះវិន័យបើពោលដោយសង្ខេបមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ្លើ. មានពីរយ៉ាងគឺ អាគារិយវិន័យ វិន័យសម្រាប់អ្នកមានផ្ទះសំបែងមួយ , អនាគារិយវិន័យ វិន័យសំរាប់អ្នកបួសមួយ ។

សួ. អ្វីហៅថាវិន័យ ? វិន័យនោះបើបព្វជិតប្រតិបត្តិតាមហើយ នឹងឲ្យប្រយោជន៍ដូចម្ដេច ?

ឆ្លើ. ពុទ្ធព្រឹត្យ ឬ ច្បាប់សម្រាប់ទូន្មាន ហាត់ពត់កាយវាចាឲ្យមានរបៀបរៀបរយ នឹងមានសណ្ដាប់ធ្នាប់ល្អ ១ ដូច្នេះហៅថាវិន័យ ។ ម្យ៉ាងទៀត ពុទ្ធបញ្ញត្តិ និង អភិសមាចារ រួមហៅថាវិន័យ ។ បើបព្វជិតប្រតិបត្តិតាមឲ្យបានត្រឹមត្រូវហើយ អាចសម្រេចប្រយោជន៍ក្នុងការរក្សាសង្ឃមណ្ឌល ឲ្យតាំងនៅបានល្អ និងដើម្បីហាមប្រាមផល់ពួកភិក្ខុជាអលជ្ជីឲ្យពាលពាញ់ ជាហេតុនាំឲ្យភិក្ខុលជ្ជីមានសេចក្ដីក្សាសប្បាយ ជាអ្នកប្រតិបត្តិវិន័យបានទទួលនូវអានិសង្ស គឺនាំឲ្យមានកិរិយាមារយាទត្រឹមត្រូវល្អ

មានទីស្រ័យល្អ មិនឲ្យមាន មានះ ទិដ្ឋិ ព្រោះហេតុនៃការប្រកាន់ជាតិ, ត្រកូលខ្ពស់ទាប បំបាត់នូវសេចក្ដីក្ដៅក្រហាយចិត្ត ដែលហៅថាវិប្បដិសារឲ្យមានបីតិប្រាមោទ្យរីករាយចិត្ត ព្រោះឃើញខ្លួនប្រព្រឹត្តល្អជាភិក្ខុត្រឹមត្រូវបរិសុទ្ធ ដែមតាំនមិនជាទីទំនាស់ដល់ក្នុកនៃជនដទៃ ។

## បួស ២ យ៉ាងគឺ

១– ពាហិរបព្វជ្ជា បួសខាងក្រៅព្រះពុទ្ធសាសនា ។

២– ធម្មវិនយបព្វជ្ជា បួសក្នុងធម៌វិន័យរបស់ព្រះពុទ្ធ ។

ធម្មវិន័យបព្វជ្ជាបើចែកតាមគោលដើមមាន ២ យ៉ាងគឺ

១- បួសជាសាមណេរ ហៅថា បព្វជ្ជា ។

២- បួសជាភិក្ខុ ហៅថា ឧបសម្បទា ។

បួសនេះបើចែកតាមប្រភេទមាន ៦ យ៉ាងគឺ

១- ឧបកីឡិកា បួសលេងល្បែង ។

២- ឧបជីវិកា *បួសគ្រាន់តែចិញ្ចឹមជីវិត* ។

៣- ឧបមុយ្សិកា *បួសខ្ជិលរៀនសូត្រ* ។

៤- ឧបទូស្សិកា *បួសគ្រាន់តែប្រទូស្តសាសនា* ។

៥- ឧបចិណ្ណិកា *បួសដើម្បីសន្សំទ្រព្យ* ។

៦- ឧបនិស្សរណា *បួសដើម្បីចេញចាកកាម* ។

ទោស ៥ យ៉ាងដែលភិក្ខុចូលទៅកាន់ត្រកូលហួសវេលា

១- មាតុគាមស្ស អភិណ្ហទស្សនំ *បានឃើញមាតុ-គ្រាមញយ ១* ។

២- ទស្សនេ សតិ សំសគ្គោ *កាលបើឃើញហើយ នាំឲ្យមានចិត្តជាប់ជំពាក់ចំពោះមាតុគ្រាមនោះ* ។

៣- សំសគ្គេ សតិ វិឡ្សាសោ *កាលបើមានចិត្តជាប់ជំពាក់ហើយ សេចក្ដីស្និទ្ធស្នាលក៏កើតមានឡើង* ។

៤- វិស្សាសោ សតិ ឱតារោ *កាលបើមានសេចក្ដី*

ស្ថិតស្ថេរ ហើយការពុះពារឡើងនៃកត្តៈកំកើតសាខ ៗ

៥- ឧតិណ្ណចិត្តស្សេតំ ភិក្ខុនោ បាដិកង្ខំ ទោស នេះរមែងប្រាកដដល់ភិក្ខុដែលមានចិត្តត្រូវពត់ៈគ្របសង្កត់ ។

ត្រកូលប្រកបដោយអង្គ ៥ ដែលបព្វជិតមិនត្រូវទៅ

១- ន មនាបេន បច្ចុដ្ឋេនន្តិ មិនក្រោកទទួលដោយសេចក្តីគោរព ។

២- ន មនាបេន អភិវាទេន្តិ មិនថ្វាយបង្គំដោយគោរព ។

៣- ន មនាបេន អាសនំ ទេន្តិ មិនឲ្យអាសនៈដោយពេញចិត្ត ។

៤- សន្តមស្ស បរិគុយ្ហន្តិ លាក់លៀមរបស់ដែលមាន ។

៥- ពហុតម្បិ ថោកំ ទេន្តិ មានច្រើនឲ្យតិច ។

៦- បណីតម្បិ លូខំ ទេន្តិ ឲ្យរបស់ថោកទាបមិន ឲ្យរបស់ថ្លៃថ្នូរ ។

៧- អសក្កច្ចំ ទេន្តិ អសកច្ចំ ឲ្យដោយមិនគោរព មិនឲ្យដោយគោរព ។

៨- ន ឧបកិសីទន្តិ ធម្មស្សវនាយ មិនអង្គុយ ដើម្បីស្តាប់ធម៌ ។

៩- ភាសិត[illegible] ន របិស្សន្តិ មិនត្រេកអរចំពោះ ការសំដែងនៃបុព្វជិត ។

អ្នកទ្រទ្រង់វិន័យមានអានិសង្ស ៥ យ៉ាងគឺ

១- អត្តនោ សីលគន្ធោ សុគុត្តោ សុរក្ខិតោ សីលក្ខន្ធរបស់ភិក្ខុគ្រងទ្រង់បានហើយរក្សាទុកបានដោយល្អ ។

២- កុក្កុច្ចបកតានំ បដិសរណំហោតិ បានជាទី ពឹងនៃពួកភិក្ខុដែលមានសេចក្តីសង្ស័យជាប្រក្រតីក្នុងវិន័យ ។

៣- វិសារទោ សង្ឃមជ្ឈេ វោហរតិ *ក្លៀវក្លា និយាយធម៌អាថ៌ក្នុងកណ្ដាលជំនុំសង្ឃ ។*

៤- បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ *សង្កត់សង្កិនដោយល្អ នូវពពួកជនដែលជាសត្រូវដោយសហធម៌ គឺសិក្ខាបទ ដែលព្រះពុទ្ធបានបញ្ញត្តិហើយ ។*

៥- សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ *ឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំមួនបាន ។*

*ព្រះបរមគ្រូទ្រង់បញ្ញត្តិវិន័យ ព្រោះអាស្រ័យអំណាចនៃ*

ប្រយោជន៍ ១០ យ៉ាងគឺ

១- សង្ឃ សុដ្ឋុតាយ *ដើម្បីសេចក្ដីល្អដល់សង្ឃ ។*

២- សង្ឃ ផាសុតាយ *ដើម្បីការសម្រួលដល់សង្ឃ ។*

៣- ទុម្មង្កូនំ ភិក្ខូនំ និគ្គហាយ *ដើម្បីញាំញីពួកភិក្ខុទ្រុស្តសីល ។*

៤- បេសលានំ ភិក្ខូនំ ផាសុវិហារាយ ដើម្បីជាសេចក្ដីសុខដល់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។

៥- ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ដើម្បីឃាត់នូវអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ។

៦- សម្បរាយិកានំ អាសវានំ បដិឃាតាយ ដើម្បីឃាត់នូវអាសវទាំងឡាយក្នុងបរលោក ។

៧- អប្បសន្នានំ បសាទាយ ដើម្បីញ៉ាំងពួកជនដែលមិនជ្រះថ្លាឲ្យជ្រះថ្លាឡើង ។

៨- បសន្នានំ ភិយ្យោភាវាយ ដើម្បីញ៉ាំងពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ។

៩ សទ្ធម្មដ្ឋិតិយា ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យតាំងនៅឋិតថេរ ។

១០ វិនយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រះវិន័យ (៤ យ៉ាង មានបហានវិន័យជាដើម ។

## អនាគារិយវិន័យមាន ៤ យ៉ាងគឺ

សំវរវិន័យមួយ ១, បហានវិន័យ ១, សមថវិន័យមួយ ១, និងបញ្ញត្តិវិន័យ ១ ។

### ក សំវរវិន័យមាន ៥ យ៉ាងគឺ

១- សីលសំវរៈ ការសង្រួមក្នុងបាដិមោក្ខ ។

២- សតិសំវរៈ ការសង្រួមក្នុងឥន្ទ្រិយទាំង ៦ ។

៣- ញាណសំវរៈ ការសង្រួមបំបាត់តណ្ហាដោយបញ្ញា ។

៤- ខន្តិសំវរៈ ការសង្រួមអត់ធន់ចិត្តក្តៅត្រជាក់ ។

៥- វីរិយសំវរៈ ការប្រឹងប្រែងមិនឲ្យវិតក្កចូលបៀតបៀន

### ខ- បហានវិន័យមាន ៥ យ៉ាងគឺ

១- តទង្គប្បហាន បានដល់ការលះកិលេសជាខណៈៗ គឺត្រូវលះដោយការធ្វើទាន, សីល, ភាវនា ។

២– វិក្ខម្ភនប្បហាន បានដល់ការល្ហេចល្ហ័នូវនីវរណ ទាំង ៥ ឲ្យស្ងប់រម្ងាប់ គឺត្រូវលះដោយ សីល-សមាធិ-បញ្ញា ។

៣– សមុច្ឆេទប្បហាន បានដល់អរិយមគ្គ ដែលលះកិលេស គឺលះដោយមិនកើតឡើងបាន ។

៤· បដិប្បស្សទ្ធិប្បហាន បានដល់អរិយផលដែល លះកិលេស ។

៥– និស្សរណប្បហាន បានដល់ព្រះនិព្វានដែល លះកិលេស ។

## កាលិកមាន ៤ យ៉ាងគឺ

១ យាវកាលិក មានកំណត់កាលពីព្រឹមពេលព្រឹកទៅ ទល់នឹងថ្ងៃត្រង់ , ដូចជាបាយ , ត្រីសាច់ នំ ចំណីជាដើម ។

២– យាមកាលិក មានកំណត់កាល ពីព្រឹម១ថ្ងៃ១យប់ ដូចទឹកអដ្ឋបាន ៨ យ៉ាង មានទឹកបានធ្វើអំពីផ្លែស្វាយជាដើម។

៣– សត្តាហកាលិក មានកំណត់កាល ៧ ថ្ងៃ បាន

ផល់ភេសជ្ជៈ ៤ យ៉ាង មានទឹកដោះគោ, ទឹកខាប់, ប្រេង ស្ករអំពៅជាដើម ។

៤ **យាវជីវិក** មានកំណត់កាលលុះត្រាតែអស់ ដូចជាភេសជ្ជៈជាថ្នាំកែរោគ ។

ស. នៅក្នុងនិស្សគ្គិយបាចិត្តិយនិទ្ទេស មានការនិយាយជាប់ទាក់ទងដោយរឿងចីវរជាច្រើន, ជាហេតុនាំឲ្យមានការឆ្ងល់ថា អកាលចីវរ, អច្ចេកចីវរ អតិរេកចីវរ នោះមានសេចក្ដីផ្សេងគ្នាយ៉ាងណា ? សូមវែកញែកឲ្យបានច្បាស់លាស់ ។

ឆ ចីវរដែលភិក្ខុបានមកនៅខាងក្រៅចីវរកាល, ក្រៅនៃអានិសង្សកឋិន លោកហៅថា „អកាលចីវរ„ ចាប់តាំងពីថ្ងៃ ៥ កើតខែអស្សុជទៅដល់ ១០ ថ្ងៃ បើមានទាយក ទាយិកាគេប្រញាប់ប្រញាល់ប្រគេនសំពត់ដោយព្រោះនូវហេតុ ណាមួយ សំពត់យ៉ាងនេះហៅថា „អច្ចេកចីវរ„ ។

សំពត់ដែលសល់លើសពីត្រៃចីវរនៅប្រក្រតីយ៉ាងតូចបំផុត

មានបណ្ដោយ ៨ ធ្នាប់ ទទឹង ៤ ធ្នាប់ ហៅថា (អតិរេកចីវរ) ។

សូមបញ្ជាក់ថា អកាលចីវរ និង អតិរេកចីវរ មានន័យដូចគ្នា ខុសគ្នាតែត្រង់បានមកមិនស្របពេលគ្នាប៉ុណ្ណោះ ប៉ុន្តែជាចីវរក្រៅពីត្រៃចីវរ ជាប្រក្រតីដូចគ្នា ។

ស. ពាក្យថាត្រៃសិក្ខា, ធម៌វិន័យ និង សាសនា ទាំង ៣ នេះ មានសេចក្ដីផ្សេងគ្នាយ៉ាងណា ? ឬ ក៏ដូចគ្នា ?

ឆ. ផ្សេងគ្នាដោយព្យញ្ជនៈ តែជាសភាវៈដូចគ្នាដោយអត្ថ សីលសិក្ខា និង បញ្ញាសិក្ខា ជាផ្នែកខាងកាយ និងវាចា បានខាងព្រះវិន័យ, ចិត្តសិក្ខា និង បញ្ញាសិក្ខា ដែលជាការប្រតិបត្តិខាងផ្លូវចិត្ត រួមចូលក្នុងផ្លូវធម៌ផង ធម៌ និង វិន័យនេះ ជាឱវាទរបស់ព្រះពុទ្ធជាភាសដូចគ្នា រួមទាំងអស់ទៅហៅថា (សាសនា) ដែលប្រែថាពាក្យប្រៀនប្រដៅនេះឯង ។

ស. ទីណាមួយដែលគេតុបតែងល្អក្ដី ជញ្ជាំងលាបថ្នាំ ផ្សេង ៗ ក៏ស្អាតស្អំក្ដី បើបព្វជិតគោះកំទេចបារីពេល គន្លុយ

ចារី ឬ ខាកស្តោះទឹកមាត់ដាក់លើទីនោះ តើត្រូវទោសអ្វី ? ចូរឆ្លើយតាមភេទជាភិក្ខុ ឬ សាមណេរ ។

ឆ. បើភិក្ខុប្រព្រឹត្តកន្លងបែបនេះត្រូវអាបត្តិទុក្កដ ។ បើសាមណេរវិញត្រូវទណ្ឌកម្ម ។

ស. បព្វជិតមិនមានជម្ងឺ បន្ទោរបង់ឧច្ចារៈ ឬ បស្សាវៈ ស្តោះទឹកមាត់ដាក់លើវត្ថុមានពណ៌ស្រស់ ខៀវ បៃតង ជាដើម មានស្មៅជាដើម តើត្រូវទោសអ្វី ?

ឆ បើភិក្ខុត្រូវអាបត្តិទុក្កដ តែបើសាមណេរវិញត្រូវទណ្ឌកម្ម ។

ស ពាក្យថា សិក្ខា និង សិក្ខាបទ ទាំងពីរម៉ាត់នេះ មានសេចក្តីអធិប្បាយដូចម្តេច ?

ឆ ពាក្យថាសិក្ខា ប្រែថា ការសិក្សា , ការរៀនសូត្រ ស្វាធ្យាយន៍, ការធ្វើកាយវាចាឲ្យថ្នឹក ឲ្យស្ទាត់មិនឲ្យគ្នាំគ្នង គឺជាធម្មជាតិដែលបុគ្គលត្រូវរៀនសូត្រ ។

រីឯពាក្យថា សិក្ខាបទវិញ បានដល់វិន័យបញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់បាន លើកឡើងជាប្រការមាត្រាមួយ ៗ ហៅថាសិក្ខាបទ ១ នោះមាននៅក្នុងបាដិមោក្ខខ្លះ មិនមានក្នុងបាដិមោក្ខខ្លះ ។ ឯសិក្ខាបទដែលមានក្នុងបាដិមោក្ខនោះគឺ: បារាជិក ៤, សង្ឃាទិសេស ១៣, អនិយត ២, និស្សគ្គិយបាចិត្តិយ ៣០, សុទ្ធិកបាចិត្តិយ ៩២ , បាដិទេសនីយ ៤, សេក្ខិយវត្ត ៧៥ រួមជា ២២០ រាប់អធិករណសមថៈ ៧ ផង ត្រូវជា ២២៧ ។

ស. ចតុប្បារិសុទ្ធិសីលមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. ចតុប្បារិសុទ្ធិសីលមាន ៤ យ៉ាងគឺ បាដិមោក្ខសំវរសីល ១, ឥន្ទ្រិយសំវរសីល ១, អាជីវបារិសុទ្ធិសីល ១ និងបច្ចយសន្និស្សិតសីល ១ ។

ស. ចុះនៅក្នុងឥន្ទ្រិយសំវរសីល ដូចម្តេច ហៅថាឥន្ទ្រិយ ? ឥន្ទ្រិយនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ការសង្រួម

ក្នុងឥន្ទ្រិយទាំងនោះត្រូវធ្វើដូចម្ដេច ? ចូរអធិប្បាយ ?

ឆ្ល ឥន្ទ្រិយ ប្រែថា ធម្មជាតិជាធំ ដូចមានវិគ្រោះថា : ឥន្ទតិ បរមិស្សរិយំ ករោតីតិ › ឥន្ទ្រិយំ ( ធម្មជាតិ ) ធម្មជាតិណា ជាធំ គឺធ្វើនូវភាពនៃខ្លួនជាធំយ៉ាងក្រៃលែងធម្មជាតិនោះ ឈ្មោះឥន្ទ្រិយ ឥន្ទ្រិយនោះមាន ៦ យ៉ាងគឺ :

១— ចក្ខុន្ទ្រិយ ឥន្ទ្រិយ គឺ ភ្នែក

២— សោតិន្ទ្រិយ ឥន្ទ្រិយ គឺ ត្រចៀក

៣— ឃានិន្ទ្រិយ ឥន្ទ្រិយ គឺ ច្រមុះ

៤— ជិវ្ហិន្ទ្រិយ ឥន្ទ្រិយ គឺ អណ្ដាត

៥ កាយិន្ទ្រិយ ឥន្ទ្រិយ គឺ កាយ

៦— មនិន្ទ្រិយ ឥន្ទ្រិយ គឺ ចិត្ត

អធិប្បាយថា : ពាក្យថា សំវរៈ ប្រែថា ការសង្រួមបិទបាំង រាំង - ប្រយ័ត្ន មិនឲ្យអារម្មណ៍ទាំងឡាយគឺរូប សម្លេង ក្លិន រស ខឹង សម្ផស្ស ធម៌ណាមួយដែលជាទោសកើតឡើង

បាន រួមសេចក្ដីមកហៅថា ឥន្ទ្រិយសំវរសីល គឺ ការសង្រួមនូវឥន្ទ្រិយ ។

ស. បើបានសង្រួមឥន្ទ្រិយហើយ តើភិក្ខុ សាមណេរបាន អានិសង្សយ៉ាងណា ? ចូរអធិប្បាយពន្យល់ ?

ឆ. បើភិក្ខុ សាមណេរ បានសង្រួមនូវឥន្ទ្រិយដ៏ម៉ត់ចត់ ហើយរមែងបាននូវសេចក្ដីសុខលើសប្រមាណ មានសុខក្នុងឈានទិព្វសុខក្នុងមគ្គផលជាដើម ។ ផ្ទុយទៅវិញ បើមិនបានសង្រួមទេ ត្រូវបានទទួលនូវការនិន្ទាតិះដៀលអំពីសំណាក់វិញ្ញូជនក្នុងបច្ចុប្បន្ននេះផង , លុះដល់ធ្វើកាលកិរិយា ទៅកាន់លោកខាងមុខនឹងបានទៅកាន់ទុគ្គតិគឺនរក ប្រេត តិរច្ឆាន ជាប្រត្យក្ស បើមិនមួយក៏មួយដែរខានពុំបានឡើយ ។

ស. ពាក្យថា បច្ច័យ ក្នុងបច្ចយសន្និស្សិតសីលបានសេចក្ដីជាដូចម្ដេច ? បច្ច័យនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. ពាក្យថា បច្ច័យបានសេចក្ដីថា គ្រឿងដែលបុគ្គលត្រូវ

អាស្រ័យ បរិភោគ ប្រើប្រាស់ ហើយប្រព្រឹត្តទៅបាន ។ សត្វទាំងឡាយក្នុងពិភពលោកយើងនេះ សុទ្ធតែត្រូវពឹងពាក់អាស្រ័យនៅលើបច្ច័យនេះទាំងអស់ ។ ដោយហេតុណាស់ក៏ត្រូវការបច្ច័យណាមួយដែរ ក្នុងបច្ច័យទាំង ៤ នេះទើបញុំាងខន្ធនៃជីវិតឲ្យមានដំណើរទៅបាន ، បើមិនអាស្រ័យសោះទេ ក៏មនុស្សក្នុងលោកនេះ មិនអាចរស់នៅបានដែរ ។

## បច្ច័យ ៤ នោះគឺ

១ – ចីវរបច្ច័យ

២ – បិណ្ឌបាតបច្ច័យ

៣ – សេនាសនបច្ច័យ

៤ – គិលានភេសជ្ជបច្ច័យ

សរ ការពិចារណានូវបច្ច័យទាំង៤នោះហៅថាអ្វី ? មានន័យដូចម្ដេច ? ក្នុងបច្ច័យមួយ ៗ មានបច្ចវេក្ខណៈប៉ុន្មាន ? គឺអ្វីខ្លះ ? ក្នុងបច្ចវេក្ខណៈនិមួយ ៗ មានសេចក្ដីដូចម្ដេចខ្លះ ? ចូរអធិប្បាយ ។

ឆ. ការពិចារណានូវបច្ច័យទាំងនោះ ហៅថា បច្ចវេក្ខណៈ មានន័យថា ការគិត ។ ការរិះគិត ការត្រិះរិះ សង្កេត-ពិនិត្យ ល្អិតល្អន់ល្អិតសេចក្ដីឲ្យយល់ជាក់ពុំមែនគ្រាន់តែសូត្រឲ្យគ្រាន់តែរួចហើយពុំយល់សេចក្ដីថាម៉េចនោះទេ ។

## ក្នុងបច្ច័យនិមួយ ៗ មានបច្ចវេក្ខណៈ ៤ គឺ

១– ធាតុប្បច្ចវេក្ខណៈ

២ – បដិកូលប្បច្ចវេក្ខណៈ

៣– តង្ខណិកប្បច្ចវេក្ខណៈ

៤– អតីតប្បច្ចវេក្ខណៈ

LIBRARY BUDDHIST INSTITUTE

ក្នុងបច្ចវេក្ខណៈនិមួយ ៗ មានសេចក្ដីអធិប្បាយដូចតទៅ៖ កាលបើបព្វជិតបានទទួលនូវបច្ច័យណាមួយ ទោះជាចីវរ-ប្បច្ច័យក្ដី បិណ្ឌបាតប្បច្ច័យក្ដី សេនាសនប្បច្ច័យក្ដី គិលាន-ភេសជ្ជប្បច្ច័យក្ដី ត្រូវតែពិចារណាក្នុងពេលជំណាលគ្នានឹងការទទួលនូវបច្ច័យនោះឯង ។

ឯការពិចារណានេះ ទោះបីមួយចប់ក្តី ឬ ច្រើនចប់ក្តី ក្នុងរយៈពេល ២៤ ម៉ោង ក៏បានតាមគួរដល់ការប្រគប ។

ម្យ៉ាងទៀតធ្វើការគោរពចិត្ត គឺពិតពិចារណាក្នុងចិត្តមានលក្ខណៈតាមលក្ខណៈនៃបច្ចវេក្ខណៈវិធីនោះ ។

ស. បច្ចវេក្ខណកាលគឺកាលដែលត្រូវពិចារណាមានប៉ុន្មាន ? គឺអ្វីខ្លះ ? រួមកាលទាំងអស់ដែលត្រូវពិចារណាមានប៉ុន្មាន ? ចូរអធិប្បាយឲ្យសព្វគ្រប់មកមើល ។

ឆ បច្ចវេក្ខណកាល គឺកាលដែលត្រូវពិចារណាមាន ៣ យ៉ាង ។

១. បដិលាភកាល គឺកាលកំពុងបានឬកំពុងទទួលនូវបច្ច័យ

២– បរិភោគកាល គឺកាលដែលកំពុងបរិភោគប្រើប្រាស់

៣– អតីតកាល គឺកាលដែលបានបរិភោគប្រើប្រាស់រួចហើយ រួមកាលទាំងអស់មាន ១២ ។

បណ្ដាកាលទាំង ៣ ដូចបានពោលរួចមកហើយនេះ ក្នុង

បដិលាភកាល   គឺកាលដែលកំពុងបានកំពុងទទួលបច្ច័យត្រូវពិចារណាដោយធាតុប្បច្ចវេក្ខណៈក៏បាន   ដោយបដិកូលប្បច្ចវេក្ខណៈក៏បាន ។

ក្នុងបរិភោគកាលត្រូវពិចារណាដោយតង្ខណិកប្បច្ចវេក្ខណៈ ក្នុងអតីតកាល   ត្រូវពិចារណាដោយអតីតប្បច្ចវេក្ខណៈ ។

ស. ថ្ងៃចូលព្រះវស្សាមានប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ?

ថ្ងៃចូលព្រះវស្សាមាន ២ ប្រភេទ គឺ :

១- បុរិមិកា   វស្សូបនាយិកា   ការចាំវស្សាមុន គឺកំណត់ចូលពីថ្ងៃ ១ រោច ខែ អាសាឍ ទៅដល់ថ្ងៃ ១៥ កើតពេញបូណ៌មីខែអស្សុជ ។

២ - បច្ឆិមិកា   វស្សូបនាយិកា   ការចាំវស្សាលើកក្រោយគឺកំណត់ចូលពីថ្ងៃ ១ រោច ខែស្រាពណ៍ទៅចេញនៅថ្ងៃ ១៥ កើតខែកត្តិក ។

ស. បើកាលណា ភិក្ខុសាមណេរបានចូលវស្សាត្រឹមត្រូវ

ដោយឡែកខ្លះទាត់ឡើង តើត្រូវបានអានិសង្សដែរ ឬទេ ? បើបាន តើអានិសង្សនោះមានប៉ុន្មាន ? គឺអ្វីខ្លះ ចូរពន្យល់ឲ្យក្បោះក្បាយមកមើល ?

ឧ ចំពោះកិច្ចដែលបានគង់ចាំវស្សាអស់ត្រៃមាសហើយ ព្រះពុទ្ធទ្រង់ប្រទានកម្រៃ ៥ យ៉ាង ។

## រឺឯកម្រៃអានិសង្ស ៥ យ៉ាង គឺ

១ ទៅណាមកណា មិនចាំបាច់លាភិក្ខុផងគ្នាតាមសិក្ខាបទទី ៦ នៃអចេលកវគ្គ បាចិត្តិយកណ្ឌ ។

២–ទៅណាមកណាមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ ។

៣– ទុកដាក់អតិរេកចីវរបានតាមប្រាថ្នា ។

៤ ឆាន់គណៈភោជន និងបរម្បរៈភោជនបាន ។

៥- មានសិទ្ធិត្រូវបានចីវរដែលកើតឡើងក្នុងដែនទៅចាំវស្សានោះ ។

សូមបញ្ជាក់ថា អានិសង្សទាំង ៥ យ៉ាងនេះត្រូវកំណត់

បាន ១ ខែ ចាប់តាំងពីថ្ងៃពេញបូណ៌មី ខែកត្តិកដើម ដល់ថ្ងៃខែដាច់កត្តិកនេះ ថែមតាំងបានដើម្បីក្រាលកឋិនដែលជួយលាតត្រដាងអានិសង្ស ៥ នេះឲ្យមានអាយុវែង ដល់ថ្ងៃពេញបូណ៌មីខែផល្គុនគឺពេញមួយហេមន្តរដូវទៀត ។

ស. កន្លែងដូចម្ដេចដែលព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យចាំវស្សាបាន ? កន្លែងដូចម្ដេចដែលទ្រង់ហាម ?

ឆ. ទីដែលមានសេនាសនៈប្រក់បិទបាំង និងមានទ្វារចេញចូលបាន ទីបែបនេះទើបព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យចាំវស្សាបាន ។ ហាមមិនឲ្យនៅចាំវស្សាក្នុងខ្ទមរន្ទាប ក្នុងពាង ក្នុងឆត្រ ក្នុងរន្ធប្រហោងឈើ និងប្រគាបឈើ ។

ស. បើភិក្ខុធ្វើដំណើរទៅដោយសារទេះ ទូក ឬ កប៉ាល់ ដែលមិនទាន់ដល់ទីកន្លែងដែលខ្លួនប្រាថ្នាចង់នៅចាំវស្សា ឬ ទីដែលគួរនៅចាំបាន ទទួលពេលនោះថ្ងៃចូលវស្សាក៏ដល់មក តើត្រូវប្រតិបត្តិដូចម្ដេច ?

ឆ. ក្នុងរឿងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតដល់ភិក្ខុ អ្នកធ្វើដំណើរដោយសាររទេះ ឬ ដោយទូក ដែលទៅមិនទាន់ ដល់ទីកន្លែងដែលខ្លួនប្រាថ្នា ឬ ទីដែលគួរចាំវស្សា បានទទួល ដល់ថ្ងៃចូលវស្សានោះលោកឲ្យចូលវស្សាតាមទូកឬរទេះនោះ ៗ លុះទៅដល់ទីដែលខ្លួនប្រាថ្នាហើយ សឹមចូលទៅចាំវស្សាក្នុងទី ដែលខ្លួនប្រាថ្នានោះបាន ។

សួ. ដូចម្តេចដែលហៅថា "បវារណា" ? បវារណានេះ ចាត់ចូលក្នុងសង្ឃកម្មណា ? បណ្តាសង្ឃកម្មទាំង ៤ នេះ ។

ឆ. បវារណានេះ ជាសង្ឃកម្មមួយយ៉ាង ដែលព្រះពុទ្ធ ទ្រង់បញ្ញត្តិឲ្យភិក្ខុដែលនៅចាំវស្សាគ្រប់ត្រៃមាសហើយ ។ បវា-រណានេះ លោកចាត់ចូលក្នុងបញ្ញត្តិកម្ម ។

សួ. បវារណា ប្រែថា ម៉េច ? មានប៉ុន្មានយ៉ាង ?

ឆ. បវារណា ប្រែថា ការបើកឱកាសដល់គ្នា និង គ្នា ដើម្បីប្រាថ្នាការដាស់តឿន ស្តីថាដល់គ្នា នឹងគ្នា បវារណា

នេះមាន ៩ យ៉ាងដូចនោះប្រាកដដែរ ។

ស. បវារណាដែលមាន ៩ យ៉ាង នោះចែកជាប៉ុន្មានផ្នែក ហើយផ្នែកនិមួយ ៗ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. បវារណាទាំង ៩ យ៉ាងនេះ ចែកជាផ្នែកមាន ៣ ផ្នែក ផ្នែកនិមួយ ៗ មានបី ១ គឺបវារណាដោយសំណាចថ្ងៃមាន ៣ ( ចាតុទ្ទសី - បណ្ណរសី - សាមគ្គី ) ។

បវារណាដោយសំណាចការក.មាន ៣ (សង្ឃបវារណា គណៈបវារណា · បុគ្គលបវារណា ) ។ បវារណាដោយអាការៈដែលត្រូវធ្វើមាន ៣ ដែរ ។

ស. ចូរអធិប្បាយ អំពីបវារណាដោយសំណាចអាការៈដែលត្រូវធ្វើ ?

ឆ. សេចក្តីអធិប្បាយ បវារណាការកសង្ឃត្រូវតាំងញត្តិមុន ហើយសឹមបវារណាតាមប្រក្រតី ត្រូវបវារណាមួយអន្លើម្តង ១ ៗ មៀនគ្នាតាមលំដាប់វស្សា ហើយត្រូវបវារណាមួយអន្លើជា ៣ ដង

ក្នុងករណីនេះត្រូវព្រះថេរៈ ១ អង្គ ដែលមានសមត្ថភាពឡើងប្រកាសដោយញត្តិថា ៖

សុណាតុ មេ ភន្តេ សង្ឃោ អជ្ជ បវារណា បណ្ណរសី យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តេវាចិកំ បវារេយ្យ ប្រែថា ពានប្រោស សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា បវារណាថ្ងៃនេះជាតិថី ១៥ បើសង្ឃដល់ពេលបវារណាហើយ សង្ឃគប្បីបវារណា ៣ ដង ។ លុះតាំងញត្តិដូច្នេះរួចហើយ ភិក្ខុជាសង្ឃត្ថេរត្រូវបិតអង្គុយច្រហោងផ្គងអញ្ជលី ផ្តោះមុខទៅរកសង្ឃ ហើយបវារណាថា : សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ (ទុតិយម្បិ តតិយម្បិ) ប្រែថា ម្នាលអាវុសោ ខ្ញុំសូមបវារណាចំពោះសង្ឃ ដោយការដែលឃើញក្តី ដោយឮក្តី

ដោយការដែលគ្រៀសក្តិ សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះស្តីថាមកខ្ញុំ , ខ្ញុំកាលបើឃើញទោស ធ្វើតបតី តែតិចិតមាយោចអាក្រក់នោះចេញ, ហ្លួលការសោ ខ្ញុំសូមបវារណាចំពោះសង្ឃគស់វារៈ ២ ដងជទីអស់វារៈ ៣ ដងផង ខ្ញុំនឹងធ្វើតបវិញ ដោយការការពារលូវគំនិតមិនល្អនោះចោលចេញ ។

បវារណាមួយអន្លើថា ៣ ដង នេះតាមញត្តិខាងដើម ញត្តិនេះហៅថា តេវាចិកាញត្តិ ។ បើតាំងញត្តិយ៉ាងនេះ ហើយនឹងបវារណាបន្ថយចុះមកឱ្យ ២ ឬ មួយដងវិញមិនគួរឡើយ ។

បើប្រាថ្នាថា ២ ដង ឲ្យតាំងញត្តិដូចខាងលើនេះដែរ តែបញ្ចេញពាក្យខាងចុងថា «សង្ឃោ ទ្វេវាចិកំ បវារេយ្យ» ប្រែថា : « សង្ឃគប្បីបវារណា ២ ដង , នេះហៅថា ទ្វេវាចិកាញត្តិ, បើតាំងញត្តិយ៉ាងនេះហើយ ត្រូវបវារណាមួយអន្លើ ១ ជាពីរដង ។ បន្ថយចុះមិនបាន ។

បើប្រាថ្នាបវារណា ១ អង្គ ត្រូវតាំងញត្តិដូចគ្នា ផ្លាស់តែត្រង់ពាក្យបញ្ចប់ថា «**សង្ឃោ ឯកវាចិកំ បវារេយ្យ**» ប្រែថា «សង្ឃគប្បីបវារណាថាមួយដង នេះហៅថា «**ឯកវាចិកាញត្តិ**» បើតាំងញត្តិយ៉ាងនេះហើយ បវារណាថា ២ ដង , ៣ ដងបាន កុំឲ្យតែបវារណាថាព្រម ១ គ្នា តាមវស្សាស្មើគ្នា ។

បើប្រាថ្នាបវារណា ដោយចាត់ឲ្យភិក្ខុមានវស្សាស្មើគ្នាឲ្យបវារណាថាព្រមគ្នា ត្រូវតាំងញត្តិបញ្ចប់ត្រង់ពាក្យខាងចុងថា : «**សង្ឃោ សមានវស្សិកំ បវារេយ្យ**» ប្រែថា សង្ឃគប្បីបវារណាតាមវស្សាស្មើគ្នា នេះហៅថា សមានវស្សិកាញត្តិ ។ លុះតាំងញត្តិយ៉ាងនេះហើយ ទឹងបវារណាថាប៉ុន្មានដងក៏ចេះតែបាន ។

បើតាំងញត្តិព្រមខ្លួនទៅ ដោយមិនកំណត់ឲ្យថាប៉ុន្មានដងទេ ត្រូវតាំងញត្តិបញ្ចប់ខាងចុងថា « **សង្ឃោ បវារេយ្យ** » ប្រែថា សង្ឃគប្បីបវារណា នេះហៅថា សព្វសង្គាហិកាញត្តិ ។

បើក្នុងអាវាសមានភិក្ខុដែលមិនគាប់បវារណាបាន ដោយហេតុមានវស្សាដាច់ឬ ដោយបានឧបសម្បទាក្នុងរយៈពេលចូលវស្សារួចហើយ សូម្បីមានចំនួនដល់ទៅ ៤ អង្គ លោកឲ្យប្រាប់បារិសុទ្ធិ ក្នុងពេលដែលពួកភិក្ខុក្រៅនេះ បវារណាហើយស្រេច បើមានចំនួនច្រើនជាង លោកឲ្យសូត្របាដិមោក្ខចប់សិន ទើបឲ្យភិក្ខុក្រៅនេះបវារណាក្នុងសំណាក់ភិក្ខុទាំងនោះ ។

បើក្នុងអាវាសមានភិក្ខុមិនគ្រប់ចំនួនធ្វើសង្ឃបវារណាបានគឺមានតែ ៤, ៣, ២ លោកឲ្យធ្វើគណៈបវារណា ។ បើមានភិក្ខុ ៤ អង្គឲ្យតាំងញត្តិថា « **សុណន្តុ មេ អាយស្មន្តោ អជ្ជ បវារណា បណ្ណរសី យទា យស្មន្តានិ មយំ អញ្ញមញ្ញំ បវារេយ្យាម** » ប្រែថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ, បវារណាថ្ងៃនេះ ជាតិថីទី ១៥ បើបវារណាកម្មមានកាលដ៏គួរដល់លោកដ៏មានអាយុទាំងឡាយហើយ , យើងគប្បីបវារណា រវាងគ្នានិងគ្នាទៅវិញទៅមក ។

បើមានភិក្ខុតែ ៣ អង្គ ឲ្យតាំងញត្តិថា : **អាយស្មន្តោ** ជំនួស **អាយស្មន្តា** ។ បើមានតែ ២ អង្គ មិនបាច់តាំងញត្តិទេ ។

ស. ពាក្យថា បាដិមោក្ខ ប្រែថាដូចម្ដេច? ព្រោះញែកសព្ទដូចម្ដេចខ្លះ បានជាប្រែយ៉ាងនេះ? បាដិមោក្ខនោះជាពាក្យហៅថានូវអ្វីខ្លះ ?

ឆ. ពាក្យថា បាដិមោក្ខ ប្រែថាធម្មជាតិធ្វើអ្នករក្សាឲ្យរួចខ្លួនក៏បាន ប្រែថា ធម្មជាតិជាប្រធានក្រៃលែង, ខ្ពស់បំផុត ប្រសើរបំផុតក៏បាន, ព្រោះញែកសព្ទជាពីរយ៉ាងគឺ : ទី ១ មកពី បាតិ + មោក្ខ (ប + អតិ + មោក្ខ) បាតិមោក្ខ នេះជាពាក្យហៅបានទាំងធម៌ទាំងវិន័យ ។

ស. បាដិមោក្ខមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. បាដិមោក្ខមានពីរយ៉ាងគឺ ឱវាទបាដិមោក្ខ ១ អាណាបាដិមោក្ខ ១ ។

ស. បាដិមោក្ខអ្វីដែលប្រកបដោយឧទ្ទេស ៤ ឧទ្ទេស៥

ទោសនោះ ៗ សំដែងឡើងនូវរឿងអ្វី ? បារាជិកដែលមានទោស ៤ នោះ តើនៅទោសណាមួយ ?

ឆ. កិច្ចឧបាជ៌កោក្ត គឺសង្ឃកម្មណា ដែលប្រកបដោយទោស ៤, កិច្ចបាជ៌កោក្តគឺក្តីណា បាដ៌កោក្តដូចគ្នាប្រកបដោយទោស ៤ ។ ទោសទាំងនោះសំដែងឡើងនូវរឿងដូចតទៅនេះ ៖

១– និទានុទ្ទេស សំដែងពីច្បាប់ដើម ដែលត្រូវចូលទៅធ្វើឧបោសថ និង ស្តាប់បាដ៌កោក្តដោយបាលីជាដើមថា :

សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ ។ ល ។ ឧទ្ទិដ្ឋំខោនិទានំ„ ។ បើភិក្ខុទីបាដ៌កោក្តផ្តើមឡើងថា : សុណាតុ មេ អយ្យេ សង្ឃោ ចុងចប់ដូចគ្នា ៗ

២–បារាជិកុទ្ទេស សំដែងពួកសិក្ខាបទ ដែលភិក្ខុប្រព្រឹត្តកន្លងហើយត្រូវអាបត្តិបារាជិក ។

៣– សង្ឃាទិសេសុទ្ទេស សំដែងពួកសិក្ខាបទដែល

ភិក្ខុប្រព្រឹត្តល្មើសហើយត្រូវអាបត្តិសំឃាទិសេស ។

៤- អនិយតុទ្ទេស សំដែងការវិនិច្ឆ័យអាបត្តិក្នុងរឿងដែលមានវត្ថុជាកស្តុតាងមិនពិតប្រាកដ ។

៥- វិត្ថារុទ្ទេស សំដែងរឿងពិស្តារតែពួកសិក្ខាបទដែលភិក្ខុប្រព្រឹត្តល្មើសហើយ ត្រូវអាបត្តិបាចិត្តិយបាដិទេសនីយ, ទុក្កដ និងអធិករណសមថ ។

បាដិមោក្ខដែលមានឧទ្ទេសតែ៤ គឺខ្វះអនិយតុទ្ទេស១ ។

បញ្ហាប្រឡងចេញឆ្នាំ១៩៦៥ ។

ស ១ ភិក្ខុត្រូវអាបត្តិបារាជិក ឈ្មោះថាដាច់សិទ្ធិជាភិក្ខុភាព ។ តែគេចង់ដឹងថា ដល់ថ្ងៃក្រោយ បើអ្នកនោះចូលមកសុំខមាទោសនិងសង្ឃ តើសង្ឃអាចអត់ទោសឲ្យហើយអនុញ្ញាតឲ្យបព្វជ្ជា ឬឧបសម្បទាបានដែរឬទេ ?

ឆ សង្ឃអាចអនុញ្ញាតឲ្យបព្វជ្ជាបាន តែឧបសម្បទាមិនបានទេ ។

២— ស. ភិក្ខុមានអធ្យាស្រ័យ ជាប្រយោជន៍បានសំដែងធម៌ទូន្មានមាតុគ្រាមតែពីរនាក់ដែលមិនមានបុរសដឹងក្តីនៅជាមួយផង ចំនួន ២០ ម៉ាត់ តើភិក្ខុនោះត្រូវអាបត្តិដែរឬទេ ? បើត្រូវ តើត្រូវដោយអាបត្តិអ្វី ? ឈ្មោះសមុដ្ឋានអ្វី ?

ឆ. ភិក្ខុនោះឈ្មោះថា ត្រូវអាបត្តិយ៉ាងពិតប្រាកដគឺ អាបត្តិបាចិត្តិយ ដោយសមុដ្ឋានទី ៧ ឈ្មោះធម្មទេសនាសមុដ្ឋាន ។

៣— ស. ក្នុងព្រះវិន័យមានចែកការកសង្ឃសម្រាប់ធ្វើសង្ឃកម្មជាប៉ុន្មានពួក ? អ្វីខ្លះ ? ហើយពួកណាមានសមត្ថកិច្ចក្នុងសង្ឃកម្មណា ?

ឆ. ក្នុងព្រះវិន័យមានចែកការកសង្ឃ សម្រាប់ធ្វើសង្ឃកម្មជា ៥ ពួកគឺ :

១ សង្ឃចតុវគ្គ មានភិក្ខុ ៤ រូប

២ សង្ឃបញ្ចវគ្គ មានភិក្ខុ ៥ រូប

៣– សង្ឃទសវគ្គ មានភិក្ខុ ១០ រូប

៤– សង្ឃវីសតិវគ្គ មានភិក្ខុ ២០ រូប

៥– សង្ឃអតិរេកវីសតិវគ្គ មានភិក្ខុលើសពី ២០ រូប ។

សង្ឃចតុវគ្គមានសមត្ថកិច្ចក្នុងសង្ឃកម្មទាំងអស់ លើកលែងតែបវារណាកម្ម , កឋិនកម្ម , ឧបសម្បទាកម្មនិងអព្ភានកម្មចេញ ។

សង្ឃបញ្ចវគ្គ មានសមត្ថកិច្ចក្នុងសង្ឃកម្មគ្រប់ទាំងអស់ លើកលែងតែ ឧបសម្បទាកម្មក្នុងមជ្ឈិមប្រទេស និងអព្ភានកម្មចេញ ។

សង្ឃទសវគ្គៈ មានសមត្ថភាពធ្វើកម្មបានទាំងអស់ លើកលែងតែ អព្ភានកម្មមួយចេញ ។ សង្ឃវីសតិវគ្គទាំងពីរនេះ មានសមត្ថភាព អាចធ្វើសង្ឃកម្មបានទាំងអស់ ឥតមានហាមឡើយ ។

៤ - ង. សង្ឃកម្មដែលត្រូវធ្វើដោយវិធីកាំងញត្តិមាន

ប៉ុន្មាន? គឺអ្វីខ្លះ? ការសូត្រផ្ទេរកឋិនចីវរទៅលោកក្រាលគ្រង និងការផ្តន្ទាទោសដល់ភិក្ខុដែលមានកំហុស ដោយតជ្ជនីយកម្មជាដើម ចាត់ចូលក្នុងសង្ឃកម្មអ្វីខ្លះ ?

ឆ. សង្ឃកម្មដែលធ្វើដោយវិធីតាំងញត្តិ មាន ៣ គឺ៖ ញត្តិកម្ម ១, ញត្តិទុតិយកម្ម ១, និងញត្តិចតុត្ថកម្ម ១ ។

ការសូត្រផ្ទេរកឋិនចីវរទៅលោកក្រាលគ្រង ចាត់ចូលក្នុងញត្តិទុតិយកម្ម, ឯការផ្តន្ទាទោសដល់ភិក្ខុដែលមានកំហុសដោយតជ្ជនីយកម្មជាដើមចាត់ចូលក្នុងញត្តិចតុត្ថកម្ម ។

សរ. កម្មដូចម្តេចហៅថា អបលោកនកម្ម ? កម្មនេះត្រូវធ្វើដោយការប្រជុំភិក្ខុប៉ុន្មានរូប ? តើធ្វើចំពោះរឿងអ្វី ? ក្នុងទីដូចម្តេច ? ចាត់ចូលក្នុងសង្ឃកម្មណា ? ចូរដោះស្រាយផ្តល ។

សរ. ដូចម្តេចហៅថា សង្ឃកម្ម ? សង្ឃកម្មនេះមានរបៀបធ្វើប៉ុន្មានប្រការ ?

ឆ. ការងាររបស់សង្ឃហៅថា សង្ឃកម្ម, មានចំនួនភិក្ខុ

តាំងពី ៤ រូបឡើងទៅហៅថា សង្ឃកម្ម ។

សង្ឃកម្មនេះមានរបៀបធ្វើ ៤ ប្រការគឺ :

១- អបលោកនកម្ម

២ ញត្តិកម្ម

៣- ញត្តិទុតិយកម្ម

៤- ញត្តិចតុត្ថកម្ម

ស· សង្ឃកម្មទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ? ចូរចែកញែក ។

ឆ.សង្ឃកម្មទាំង៤យ៉ាងនេះមានសេចក្តីអធិប្បាយដូចតទៅះ

១–អបលោកនកម្ម បានដល់កម្មដែលធ្វើដោយវិធីមិនបាច់តាំងញត្តិ គឺនិយាយប្រកាសតែម្តងមិនបានសូត្រអនុស្សាវនា គឺការបញ្ជាក់សេចក្តីសម្រេចយល់ព្រមរបស់សង្ឃ គ្រាន់តែប្រកាសប្រាប់សង្ឃប៉ុណ្ណោះជាការស្រេច ។ ដូចជាអបលោកន៍ក្នុងការចែកភាគអាហារជាដើម ។

២- ញត្តិទុតិយកម្ម បានដល់ការដែលសូត្រញត្តិ ប៉ុន្តែមិនបាច់សូត្រអនុស្សាវនាផងទេ ។ ឧទាហរណ៍ដូចជាតាំងញត្តិឲ្យសង្ឃធ្វើឧបោសថជាអាទិ ។

៣ ញត្តិទុតិយកម្ម បានដល់កម្មដែលមានសូត្រអនុស្សាវនា និងញត្តិជាគម្រប់ពីរ ដូចជាសំដែងទីសម្រាប់ស្ថាបនាកុដិឲ្យដល់ភិក្ខុ ។

៤- ញត្តិចតុត្ថកម្ម បានដល់កម្មមានអនុស្សាវនា ៣ និងញត្តិ ១ ។ ដូចការផ្ដន្ទាទោសដល់ភិក្ខុ ដែលកំពុងនៅបរិវាសកម្ម ត្រូវអាបត្តិសង្ឃាទិសេស ឲ្យត្រឡប់ប្រព្រឹត្តល្អឡើងវិញ ។

ស ពាក្យថា ឧបោសថនេះជាឈ្មោះអ្វី ? ប្រែថាម៉េច ? ចូរអធិប្បាយព្រមទាំងពន្យល់ឲ្យបានច្បាស់លាស់មកមើល ។

ឆ. ពាក្យថា ឧបោសថនេះ ជាឈ្មោះនៃការប្រព្រឹត្តវត្តម្យ៉ាងមានការអត់អាហារជាគោលដៅ ហើយប្រែថាៈ ការចូលទៅនៅឬជាការចូលទៅសំអាតឲ្យស្អាតឡើងវិញ ។

ឧបោសថនេះមានតាំងពីបុរាណសម័យ មុនពុទ្ធសម័យទៅទៀត ជាតបធម៌សម្រាប់ដុតកំដៅ ឬ ដុសខាត់ខ្ជូរកិលេសម្យ៉ាង ដែលសប្បុរសជំនាន់បុរាណ នាំគ្នាកាន់ប្រព្រឹត្តក្នុង ១ សត្តាហម្តង ត្រូវគ្នានឹងថ្ងៃ ៨ កើត ៨ រោច ១៥ កើត ១៥ រោច ។

លុះដល់មកសម័យពុទ្ធកាល ព្រះបរមសាស្តាជាម្ចាស់ទ្រង់អនុមតិតាម តែទ្រង់ផ្លាស់កម្មវិធីឲ្យសមគួរដល់គ្រហស្ថនិងបព្វជិតដែលអាចធ្វើបាន ។

តែប៉ែកខាងឧបាសក-ឧបាសិកា ទ្រង់ឲ្យសមាទានសីល ៨ ដែលហៅថាឧបោសថសីល ហើយនិងយកការស្តាប់ធម៌សាកច្ឆាធម៌មកប្រកបចូល ត្រូវនាំគ្នាធ្វើក្នុងមួយសប្តាហ៍ម្តង តាមកំណត់ថ្ងៃដែលមានមកពីបុរាណកាល តែលុះដល់ក្រោយពុទ្ធកាលព្រះគន្ថរចនាចារ្យ បន្ថែមថ្ងៃ ៥ កើត ៥ រោចទៀត ដើម្បីឲ្យបានញឹកញយបន្តិច ។

ប៉ែកខាងភិក្ខុទ្រង់អនុញ្ញាតឲ្យធ្វើឧបោសថរាល់កន្លះខែម្តង

ផ្លាស់កម្មវិធី ដោយឲ្យប្រាប់បរិសុទ្ធដល់គ្នានិងគ្នា ។ បើមានភិក្ខុគ្រប់ចំនួនសង្ឃ ឲ្យសំដែងអាណាបាដិមោក្ខថែមទៀត ។ ឧបោសថនេះមានតែមួយទេ, ប៉ុន្តែដែលមានឈ្មោះដល់ទៅ ៩ យ៉ាង ពីព្រោះលោកចែកដោយអំណាចការកៈអំណាចថ្ងៃដែលត្រូវធ្វើ និងអំណាចអាការៈដែលត្រូវធ្វើ ។

សួ. ឧបោសថដោយអំណាចថ្ងៃគឺអ្វីខ្លះ ?

ឆ្លើ. ឧបោសថដោយអំណាចថ្ងៃគឺ :

១– ចាតុទ្ទសិកឧបោសថ ឧបោសថដែលធ្វើក្នុងថ្ងៃ ១៤ រោច ។

២– បណ្ណរសិកឧបោសថ ឧបោសថដែលធ្វើក្នុងថ្ងៃ ១៤ កើត និងថ្ងៃ ១៥ រោច ។

៣– សាមគ្គីឧបោសថ ឧបោសថធ្វើដោយសាមគ្គី (ឥតកំណត់ថ្ងៃ ។

សួ. ឧបោសថដែលធ្វើដោយការកៈ (អ្នកធ្វើ) មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ ឧបោសថដែលធ្វើដោយការកៈ (អ្នកធ្វើ) មាន ៣ យ៉ាងគឺ :

១- សង្ឃឧបោសថ ឧបោសថធ្វើដោយសង្ឃ (កំណត់យកភិក្ខុតាំងពី ៤ រូបឡើងទៅ) ។

២- គណឧបោសថ ឧបោសថដែលធ្វើដោយគណៈ មានកំណត់ភិក្ខុពី ២ រូបទៅ ៣ រូប ។

៣- បុគ្គលឧបោសថ ឧបោសថធ្វើដោយបុគ្គលម្នាក់ឯងៗ

អធិប្បាយ :

១ សុត្តុទ្ទេសឧបោសថ ឧបោសថនេះធ្វើដោយសង ព្រមទាំងមានសូត្របាដិមោក្ខផង ។

២- បារិសុទ្ធិឧបោសថ គឺឧបោសថធ្វើដោយគណៈគ្មានសូត្របាដិមោក្ខទេ គ្រាន់តែប្រាប់បារិសុទ្ធិដល់គ្នានិងគ្នាប៉ុណ្ណោះជាការស្រេច ។

៣ អធិដ្ឋានឧបោសថ ឧបោសថដែលធ្វើដោយអធិដ្ឋាន

គឺ តាំងចិត្តថា « **អជ្ជ មេ ឧបោសថោ** »

ប្រែថា « ថ្ងៃនេះជាថ្ងៃឧបោសថរបស់អញ » ។

ស. ឧបោសថប្រកបដោយអង្គប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. ឧបោសថប្រកបដោយអង្គ ៣ គឺ :

១ ថ្ងៃធ្វើឧបោសថត្រូវតាមថ្ងៃ ដែលព្រះពុទ្ធទ្រង់បញ្ញត្តិ គឺថ្ងៃ ១៤ រោច, ១៥ រោច និង ១៥ កើត ។

២- ភិក្ខុមកប្រជុំមានគ្រប់ចំនួនតាមបញ្ញត្តិគឺមានតាំងពី ៤ រូបឡើងទៅ ។

៣- ភិក្ខុទាំងនោះមិនត្រូវសភាគាបត្តិ (គឺមិនត្រូវអាបត្តិដែលមានចំណែកស្មើគ្នាដោយវត្ថុ មានការបរិភោគភោជនក្នុងវេលាវិកាលជាដើម ។

## បុព្វករណៈ

កិច្ចដែលត្រូវធ្វើមុនសង្ឃប្រជុំហៅថា បុព្វករណៈ មាន ៤ យ៉ាងគឺ,

១– សម្មជ្ជនី បោសប្រាសទីកន្លែងប្រជុំ ។

២– បទីបោ បើពេលប្រជុំនឹងទឹកត្រូវអុជប្រទីប ។

៣– ឧទកំ ចំរុងទឹកឆាន់និងទឹកប្រើប្រាស់ ។

៤– អាសនំ ត្រូវរៀបចំអាសនៈមានកន្ទេលជាដើម ។

## គាថា

សម្មជ្ជនី បទីបោ ច ឧទកំ អាសនេន ច
ឧបោសថស្ស ឯតានិ បុព្វករណន្តិ វុច្ចតិ ។

## បុព្វកិច្ច

កិច្ចដែលត្រូវធ្វើក្នុងពេលដែលសង្ឃប្រជុំគ្នាហើយ តែមុនពេលធ្វើឧបោសថ ហៅថាបុព្វកិច្ចមាន ៥ គឺ៖

១– ឆន្ទៈ ការនាំឆន្ទៈរបស់ភិក្ខុ ដែលមិនបានមកប្រជុំ ។

២– បារិសុទ្ធិ ការនាំបរិសុទ្ធិរបស់ភិក្ខុដែលបានមកប្រជុំ ។

-- [illegible]

៤- **ភិក្ខុគណនា** ការរាប់ចំនួនភិក្ខុ ។

៥- **ឱវាទោ** ការឲ្យឱវាទដល់ភិក្ខុនី ។

ឆន្ទៈ ១; បារិសុទ្ធិ ១; ការប្រាប់រដូវ ១; ការរាប់ចំនួនភិក្ខុ ១, និង ការឲ្យឱវាទដល់ភិក្ខុនី ១ ទាំង ៥ នេះហៅថា **បុព្វកិច្ច** ។

ស. ចូររៀបរាប់អំពីពិធីធ្វើឧបោសថ ៣ យ៉ាង ដោយ អាការៈដែលត្រូវធ្វើមកមើល ?

ឆ. ចំពោះសង្ឃឧបោសថ ត្រូវភិក្ខុជាថេរៈចូលទៅក្នុង រោងឧបោសថ ដាក់ឲ្យភិក្ខុជានវកធ្វើបុព្វករណ៍ ទាំង ៤ ឲ្យហើយ ស្រេច (ភិក្ខុជានវកមិនទទួលធ្វើ ត្រូវអាបត្តិទុក្កដ) ដល់ពេល សង្ឃសន្និបាតហើយ ឲ្យធ្វើបុព្វកិច្ច ៤ ដែលមាននៅដល់សព្វ ថ្ងៃនេះ តែត្រូវភិក្ខុឈ្លាសវៃមួយរូបទាំងញត្តិយ៉ាងនេះថា ៖

**«សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ (ចាតុទ្ទសោ) យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ»** ប្រែថា« ពាន ព្រះ

សូមព្រះសង្ឃស្តាប់ខ្ញុំ ឧបោសថថ្ងៃនេះ ( មានក្នុងតិថីទី ១៤) បើឧបោសថកម្មគួរដល់សង្ឃហើយ សូមសង្ឃធ្វើឧបោសថសំដែងឡើងនូវបាដិមោក្ខ„ ។ នេះជាញត្តិនៃឧបោសថធ្វើក្នុងតិថីទី ១៤ ។ បើធ្វើក្នុងតិថីទី ១៥ ឲ្យថា: „បណ្ណរសោ„ បើថ្ងៃសាមគ្គីឲ្យថាសាមគ្គី ។

## ប្រស្នាវិន័យទី ២

គ្រប់តែកិច្ចការទាំងអស់ក្នុងលោកនេះ ទាល់តែគេយល់ឃើញមានប្រយោជន៍ជាដើមសិន ទើបគេនាំគ្នាចំប្រឹងសង្វាតធ្វើការងារទាំងនោះ ចុះព្រះវិន័យវិញ តើគប្បីពិចារណាឲ្យឃើញវត្ថុបំណងរបស់សិក្ខាបទនោះៗ ដូចម្តេចខ្លះ ទើបនឹងព្យាយាមចំប្រឹងប្រតិបត្តិតាមបាន ?

គួរពិចារណាមើលនូវសេចក្តីនៃសិក្ខាបទនោះ ៗ ឲ្យឃើញថា ព្រះអង្គបញ្ញត្តិឡើងដោយប្រារភហេតុអ្វី បំណងអ្វី ហើយក៏ចំប្រតិបត្តិឲ្យសមតាមបំណងនោះ ។ គប្បីពិចារណា

ដល់ពុទ្ធប្បញ្ញត្តិដែលទ្រង់ហាមប្រាមប្រាកដចំពោះកាល ឬ ប្រទេស និងការនិយាយរបស់ខ្លួនមនុស្សក្នុងសម័យនោះ ១ ៗ លុះកន្លងកាលជាលំដាប់មកហើយមិនយកមកប្រើក្នុងសម័យដទៃ ប្រទេសដទៃប្រព្រឹត្តទៅមិនស្រួលហើយ ថែមទាំងមិនមា-អ្នកណាកែប្រែជាហេតុនាំឲ្យកិក្ខុះក្នុងកាលនោះ ប្រទេសនោះគិតបែររកផ្លូវនេះបង់ពីការប្រព្រឹត្តក៏មាន, កាលបើពិចារណាឃើញដូច្នេះហើយ គួរនាំសេចក្តីប្រតិបត្តិឲ្យសម្រេចតាមគោលបំណងព្រះវិន័យ ទើបមិនមានព្យាយាមខំប្រតិបត្តិតាម ឲ្យបានទទួលអានិសង្សអំពីសេចក្តីប្រតិបត្តិនោះឯង ៗ

ស. សម្បត្តិក្នុងព្រះពុទ្ធសាសនាគឺអ្វី ? សម្បត្តិនោះមានប៉ុន្មាន ? ចែកជាប៉ុន្មានផ្នែក ? គឺអ្វី ?

ឆ. សម្បត្តិក្នុងព្រះពុទ្ធសាសនាគឺ បច្ច័យ ៗ សម្បត្តិនោះ ១ ចែកជា ៤ ផ្នែកគឺ ចីវរ, បិណ្ឌបាត; សេនាសនៈ និងគិលានភេសជ្ជៈ ដែលទាយកទាយិកាមានសទ្ធាជ្រះថ្លាបានបូជា

ថ្វាយដល់ចេតិយដូចគ្រឿងពុទ្ធបូជា, គ្រឿងបូជាពោធិព្រឹក្សជាដើម ទុកជាភណ្ឌៈរបស់ចេតិយ ១, ដែលគេប្រគេនចំពោះភិក្ខុមួយរូប ៗ ហៅថា ភណ្ឌៈរបស់បុគ្គល ១, ដែលគេវេរថ្វាយជាប្រយោជន៍សាធារណៈដល់ភិក្ខុទាំងឡាយគឺ ដល់សង្ឃហៅថាភណ្ឌៈរបស់សង្ឃ ១ ; ។

សួ. ភណ្ឌៈរបស់សង្ឃចែកចេញជាប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ? ភណ្ឌៈនិមួយ ៗ ប្រែថាម៉េច ?

ឆ. ភណ្ឌៈរបស់សង្ឃចែកចេញជា ២ ប្រភេទគឺចីវរបិណ្ឌបាតនិងភេសជ្ជៈជាពួកមួយហៅថាលហុភណ្ឌ ។ សេនាសនៈនិងសម្ភារៈសម្រាប់សេនាសនៈនេះជាពួកមួយហៅថា គរុភណ្ឌ ។ លហុភណ្ឌ ប្រែថា ភណ្ឌ រហ័សឬ ឆាប់អស់ ឆាប់ខូច ។ គរុភណ្ឌប្រែថា ភណ្ឌយូរ ។

សួ. ភណ្ឌៈទាំងពីរប្រភេទនេះ តើសង្ឃអាចចែកគ្នាបានដែរឬទេ ?

ឆ. សង្ឃអាចចែកគ្នាបានតែលហុភណ្ឌទេ ចំណែកគរុ-

កណ្ឌសន្សំពុំអាចចែកបានទេ ព្រោះវាតែងតែមានសម័យគឺ សម័យទុរ្ភិក្ស ។

ស. គុកណ្ឌទាំងអស់មានប៉ុន្មាន ? បើចែកជាក្រុមមាន ប៉ុន្មានក្រុម ? តើក្រុមនិមួយ ៗ មានប៉ុន្មាន ? ចូររាប់ឲ្យបាន ច្បាស់លាស់មកមើល ។

ឆ. គុកណ្ឌរួមទាំងអស់មាន ៤៥ មុខ ។ បើចែកជាក្រុមមាន ៨ ក្រុមគឺ :

### ក្រុមទី ១ មាន ២ ឈ្មោះគឺ

១ - អារាមោ របស់ដាំ ឬ សានក្ដុងទីអាការ ។

២ - អារាមវត្ថុ ទីអាការ ។

### ក្រុមទី ២ មាន ២ ឈ្មោះគឺ

១ . វិហារោ កុដិជាទីនៅនោះ ។

២ . វិហារវត្ថុ ទីដីសម្រាប់សង់កុដិ ។

## ក្រុមទី ៣ មាន ៤ ឈ្មោះគឺ

១ – អរញ្ញ ព្រៃ

២ – ចីថំ គោអ៊ី, តាំង កុ

៣ – កសិ ពូក·

៤ – ពាម្ពាហន់ រទេះ ៗ

## ក្រុមទី ៤ គ្រឿងលោហៈ មាន ៩ ឈ្មោះគឺ

១ – លោហកុម្ភី ឆ្នាំងលោហៈឆ្នាំងស្ពាន់

២ – លោហភាណកំ ពានលោហៈ

៣ – លោហវារកោ ចានលោហៈ

៤ – លោហកដាហំ ខ្ទះលោហៈ

៥ – វាសី កាំបិតធំ

៦ – ផរសុ ពូថៅ

៧ – កុឋារី ដឹងចាំងឈើ

៨ – កុទ្ទាលោ ចបជីក, ចបកាប់ ៗ

៩ – និខាទនំ ពន្លាក ៗ

ក្រុមទី ៥ គ្រឿងសម្ភារសម្រាប់ធ្វើសេនាសនៈ
និងប្រដាប់សម្រាប់ប្រើប្រាស់មាន ៨ ឈ្មោះគឺ

១ - វល្លិ    វល្លិ ឬ ផ្តៅ

២ - វេឡុ    ឫស្សី

៣ - មុញ្ជ    ស្មៅដំណេកទន្សាយ

៤ - បព្វជ    ស្មៅយាប្លង

៥ - តិណ    ស្បូវ ឬ ស្មៅធម្មតា

៦ - ទារុភណ្ឌ    របស់ដែលធ្វើពីឈើ

៧ - មត្តិកាភណ្ឌ    របស់ដែលធ្វើអំពីដីដែលគេដុតដូចជា ពាង ក្រឡ ។

៨ - មត្តិកា    ដីស្អិត

ង . តើសង្ឃមានពិធីត្រូវប្រតិបត្តិដូចម្តេច ? ចំពោះគរុ-ភណ្ឌនោះ ដើម្បីដែរក្សាឲ្យបានគង់វង្ស ។

ច . សង្ឃត្រូវប្រតិបត្តិដូចតទៅនេះ ៖

១ – គុរុភណ្ឌទាំងនេះ ហាមមិនឲ្យចែកគ្នាដាច់ដោយឡែក ៗ ជាកម្មសិទ្ធិរបស់ភិក្ខុមួយរូប ៗ ទេតែគេគាប់ចែកឲ្យប្រើប្រាស់ដោយភារៈជារបស់ខ្លួនបានដែរ ភិក្ខុអ្នកចែកគុរុភណ្ឌដែលត្រូវហាមឲ្យត្រូវអាបត្តិថុល្លច្ច័យ ។ អ្នកទទួលគុរុភណ្ឌយកទៅប្រើប្រាស់ត្រូវសងវិញ ឬ សងរបស់ដទៃជំនួសវិញក៏បាន ។

២ – ការចំណាយគុរុភណ្ឌដែលអាក្រក់ ប្តូរយករបស់ល្អវិញបាន ។

៣ – ចំណាយគុរុភណ្ឌដែលមិនមានឧបការៈ យករបស់ដែលមានឧបការៈវិញបាន ។

៤– ចំណាយគុរុភណ្ឌ ឬ យកលហុភណ្ឌមកចែកគ្នាមិនបាន តែបើមានទុព្ភិក្សសម័យ អនុញ្ញាតឲ្យចំណាយរបស់អន់ ៗ ដើម្បីអាហារ ដោយប្រាថ្នានៅគង់សេនាសនៈដែលល្អ ៗ បាន ។

៥ – ចំណាយគុរុភណ្ឌ ដើម្បីប្រយោជន៍ដល់សង្ឃនោះ លោកហៅថា «ជាតិកម្ម» ។

៦  វត្ថុដែលគ្មានសង្ឃនៅ  អាចទៅរើយករបស់ផ្សេងៗ ទោះជាសង្ហារិមវត្ថុដូចជា តុ - ទូ - កៅអីក្ដី  ទោះជាសង្ហារិមវត្ថុក្ដី ដូចជាទ្វារ, បង្អួចក្ដី  យកមកប្រើប្រាស់ ឬ យកទៅបញ្ចូលជាគរុភណ្ឌក្នុងវត្តដទៃបាន តែបើវត្តនោះត្រឡប់ជាមានលោកសង្ឃនៅវិញ លោកត្រូវយកទ្រព្យទាំងនោះទៅសងវិញ ។

៧ - ពូជឈើជារបស់បុគ្គល  យកទៅបណ្ដុះដាំក្នុងផ្ទៃដីរបស់សង្ឃ  អ្នកកសិករត្រូវចែកចំណែកថ្វាយដល់សង្ឃ ឬ ឲ្យថ្លៃឈ្នួល ។

## ការលាសិក្ខា

ស . ការលាសិក្ខា  ត្រូវប្រកបដោយអង្គប៉ុន្មាន ? គឺអ្វីខ្លះ

ឆ . ការលាសិក្ខា ត្រូវប្រកបដោយអង្គ ៦ យ៉ាងគឺ :

១ ចិត្ត, ២ ខេត្ត, ៣ កាល, ៤ ប្រយោគ, ៥ បុគ្គល, ៦ ជានន  ការដឹងច្បាស់លាស់ ។

សេចក្ដីអធិប្បាយៈភិក្ខុដែលមានបំណងចង់សឹកលាចាកផ្នួស

ត្រូវតែសឹកប្រកបដោយអង្គ ៦ នេះ ទើបអាចសឹកបានដាច់ភេទជាភិក្ខុពិតប្រាកដ ។

១- ចិត្តបង់សឹកមែន ។ ។ ២- និយាយត្រូវខេត្ត, ខេត្តនោះមាន ២ ផ្នែក គឺវត្ថុដែលខ្លួនត្រូវលះលាដូចជាព្រះពុទ្ធរូប ឬវិន័យជាដើមត្រូវនិយាយថា ខ្ញុំលា ព្រះពុទ្ធ, ខ្ញុំលា ព្រះផ្នួស.. ។ ៣ និយាយឲ្យជាពាក្យបច្ចុប្បន្នកាល កុំនិយាយពាក្យអតីតកាលថាសឹកហើយ, ពាក្យអនាគតកាលថា ខ្ញុំនឹងសឹក, ពាក្យបរិកប្បថា ខ្ញុំគប្បីសឹកនោះឡើយ ។ ៤ អំពើក្នុងរឿងសឹកហៅថា " បយោគ ", អំពើនោះមាន២យ៉ាងគឺ :

**កាយិកប្បយោគ** ធ្វើដោយកាយមួយ **វាចិកប្បយោគ** ធ្វើដោយវាចាមួយ, សេចក្តីថា ការសឹកនេះ លោកឲ្យប្រើវាចានិយាយជាប្រមាណ គឺមិនត្រូវប្រើកាយិកប្បយោគ ឬសរសេរអក្សរ ឬក៏ប្រើកាយវិការមានគ្រវីក្បាល, រាដៃ, ងក់ក្បាលជាដើម

៥ - បុគ្គលនោះមាន ២ ផ្នែកគឺ ខ្លួនអ្នកសឹក១. អ្នកទទួលដឹង ១

LIBRARY

អ្នកសឹកត្រូវជាអ្នកមានប្រក្រតី គឺមិនភ្លេច, មិនស្ពន់គំនិត, មិនរវើរវាយ ។ ឯអ្នកដែលជាសាក្សីនោះត្រូវជាមនុស្សមិនភ្លេច, មិនស្ពន់គំនិត, មិនរវើរវាយដូចគ្នា ហើយត្រូវនៅក្នុងទីចំពោះមុខអ្នកសឹកនៅឆ្ងាយពីគ្នាមិនបាន ។ ៦ ការដឹងច្បាស់សំដៅយកបុគ្គលជាសាក្សីដែលអ្នកសឹកកំណត់យក១, មិនកំណត់យក១, ។

## ប្រស្នាវិន័យទី ៣

សួ. អ្វីហៅថាវិន័យ ? ព្រះពុទ្ធទ្រង់បញ្ញត្តិវិន័យ ព្រោះអាស្រ័យប្រយោជន៍ប៉ុន្មានយ៉ាង ?

ឆ. ព្រះឱវាទជាពុទ្ធអាណា ដែលព្រះអង្គបញ្ញត្តិឡើងដោយន័យពិសេសផ្សេង ៗ មានបាតិមោក្ខុទ្ទេស ៥ យ៉ាង និងអាបត្តិ ៧ កង មានបារាជិកជាអាទិ ហៅថាវិន័យ ឬព្រះឱវាទសម្រាប់ប្រដៅកាយនិងវាចាហៅថាវិន័យ ។

ព្រះពុទ្ធអង្គទ្រង់បញ្ញត្តិវិន័យព្រោះអាស្រ័យអំណាច ១០ យ៉ាង ដូចបានពោលមកខាងដើមរួចហើយ ។

ស. អ្វីហៅថាអាបត្តិ ? អាបត្តិនោះមានទោស លើខ្លួនយ៉ាងណា ? ចូរសង្គ្រោះអាបត្តិទាំងអស់ឲ្យចុះក្នុងប្រការ២ ។

ឆ. កិរិយាដែលប្រព្រឹត្តកន្លងនូវពុទ្ធប្បញ្ញត្តិហើយ ត្រូវមានទោសលើខ្លួន និង ច្បាប់ដែលព្រះពុទ្ធទ្រង់ហាម នឹងមិនធ្វើតាមអនុញ្ញាត ដែលមានបញ្ញត្តិថែមទៀតផងហៅថា អាបត្តិ ។ អាបត្តិនោះមានទោស ៣ យ៉ាងគឺ: គឺយ៉ាងធ្ងន់ ធ្វើអ្នកដែលត្រូវឲ្យដាច់ចាកជាភិក្ខុភាពនេះ បានខាងអាបត្តិបារាជិកមួយ, យ៉ាងកណ្តាលធ្វើអ្នកដែលត្រូវឲ្យនៅបរិវាសកម្ម គឺប្រព្រឹត្តវត្តមួយយ៉ាងដើម្បីឲ្យខ្លួនបានខាងអាបត្តិសង្ឃាទិសេសមួយ ។ យ៉ាងស្រាលធ្វើឲ្យអ្នកដែលត្រូវអាបត្តិផ្ទាល់ខ្លួនចំពោះមុខភិក្ខុផងគ្នា កាលបើយ៉ាងនេះ ទើបរួចចាកទោសនោះ ។ បានខាងអាបត្តិថុល្លច្ច័យជាដើម ។ សង្គ្រោះចូលក្នុងសតេកិច្ឆា មិនដាច់ចាកភិក្ខុភាវៈ១, អតេកិច្ឆា ដាច់ចាកភិក្ខុភាវៈ១, ។

ស. អតេកិច្ឆាបានសេចក្តីដូចម្តេច ? មានប៉ុន្មាន ?

ឆ. អគោចរដ្ឋាន បានសេចក្តីថា ទី ឬកន្លែងដែលបព្វជិតមិនគួរត្រាច់ទៅមាន ៦ យ៉ាងគឺ ស្រីពេស្យា១, ស្រីមេម៉ាយ១, ស្រីក្រមុំមិនទាន់មានប្តី១, កិក្ខុនិ , បណ្ឌក១, គៀមស្រា១, ។

ស. ចុះអគោចរដ្ឋានទាំង ៦ នេះ សុទ្ធតែទៅមិនបានទាំងអស់ឬអាចទៅកន្លែងខ្លះបានដែរ ?

ឆ. មិនមែនទៅមិនបានសោះនោះទេ បើស្គាល់ហេតុទៅដោយកិច្ចការដែលគួរជួបគេនិមន្តទៅទទួលភត្តជាដើម, ឬក៏បានទទួលនូវសេចក្តីទុកចិត្តអំពីគេក៏អាចទៅបានដែរ ។ ប៉ុន្តែសូមបញ្ជាក់ថា បើទៅកាន់កន្លែងទាំងប៉ុន្មាននេះ គប្បីប្រព្រឹត្តអាកប្បកិរិយាឲ្យបានសមរម្យ ។

ស. កាលិក មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូរកប់ ។

ឆ. កាលិកមាន ៤ យ៉ាងគឺ :

១ - យាវកាលិក វត្ថុដែលភិក្ខុទទួលហើយ ទុកបាន

បានមួយកាល គឺតាំងអរុណរះដរាបដល់ថ្ងៃត្រង់ ដូចជាបាយ, សម្ល, នំស្រស់- នំក្រៀមជាដើម ។

២– **យាមកាលិក** គឺរបស់ដែលទុកបរិភោគបានតែមួយយប់មួយថ្ងៃ បានដល់ទឹកបាន ៨ យ៉ាង ដែលច្រោះចេញពីផ្លែឈើ ៨ យ៉ាង មានទឹកផ្លែស្វាយ និង ផ្លែល្ពៅជាដើម ។ សូមបញ្ជាក់ថា ទឹកទាំង ៨ យ៉ាងនេះត្រូវច្របាច់យកសាច់ចេញ ហើយលាយជាមួយនឹងទឹក ឬ ថែមស្ករផងក៏បាន ហើយឆាន់ទៅមិនបាច់ចំអិនទេ តែចំពោះផ្លែម៉ាក់ប្រាងត្រូវតែលាយជាមួយនឹងទឹក ។ ក្រៅពីនោះលាយក៏បានមិនលាយក៏បាន ។

៣– **សត្តាហកាលិក** វត្ថុដែលផ្សេងពីយាវកាលិក គឺភិក្ខុទទួលប្រគេនហើយអាចទុកបាន ៧ ថ្ងៃ បានដល់ភេសជ្ជៈ ៥ យ៉ាងគឺ ទឹកដោះថ្លា, ទឹកដោះខាប់, ប្រេង ទឹកឃ្មុំ និង ស្ករអំពៅ ។

៤– **យាវជីវិក** របស់ដែលទុកបរិភោគប្រើប្រាស់ដរាប

អស់ ហៅថា ‹‹ យាវជីវិក ›› នៅក្នុងភេសជ្ជក្ខន្ធកៈ មានសំដែងទុក ៦ យ៉ាងគឺៈ ១ មូលភេសជ្ជៈ ថ្នាំដែលកើតពីឫសឬដើម ដូចជាមើមខ្ញី - រមៀត កាចម៉ទ្រឹះជាដើម ។ ២ បណ្ណ-ភេសជ្ជៈ ថ្នាំដែលកើតអំពីស្លឹក ដូចជាស្លឹកតែ, ស្ដៅ- ម្រះជាដើម ។ ៣ ផលភេសជ្ជៈ ថ្នាំដែលកើតអំពីផ្លែឈើ ដូចជាផ្លែស្រម៉ កន្ទួតព្រៃជាដើម ។ ៤ ជតុភេសជ្ជៈ ថ្នាំដែលកើតពីជ័រឈើ ដូចជាពុំសែន - កញ្ចានជាដើម ។ ៥ កសាវ-ភេសជ្ជៈ របស់មានរស់ជាតិល្វីងដូចគក់ ។ ៦ លោណភេសជ្ជៈបានដល់អំបិលគ្រប់យ៉ាង ។

ស. ដូចម្ដេចហៅថា កាលិកសំសគ្គៈ? ចូរពន្យល់ ។

ឆ. កាលិកដែលលាយច្របល់ចូលគ្នា ហៅថា កាលិក-សំសគ្គៈ ។ ដូចជាគេយកស្ករដែលជាសត្តាហកាលិក ត្រូវលាយចូលនឹងម្សៅដែលជាយាវកាលិក ត្រូវប្រតិបត្តិតាមអាយុរបស់យាវកាលិក គឺទទួលប្រគេនហើយទុកឆាន់បានអស់ពីព្រឹក

ទល់ទិនថ្ងៃត្រង់ប៉ុណ្ណោះ ឬ ក៏គេយកទឹកឃ្មុំជាសត្តាហកាលិកទៅលាយថ្នាំបុក ដែលជាយាវជីវិក ថ្នាំនេះត្រូវរស់តាមអាយុតែ ៧ ថ្ងៃ តាមទឹកឃ្មុំដែលជាសត្តាហកាលិក ។ តែបើទទួលរួមគ្នាដោយកាលិកផ្សេងគ្នា ដូចជារបស់ដែលទាយកទាយិកា ដាក់ក្នុងថាសជាមួយគ្នាមានបាយសម្ល - ស្ករ - ទឹកដោះ - ថ្នាំតែរោគផ្សេងៗ ភិក្ខុអាចញែករបស់ទាំងអស់នោះទុកឆាន់តាមកាលិកផ្សេងគ្នាបាន ។ មួយទៀត សត្តាហកាលិកទុកគ្រប់ ៧ រាត្រីហើយ មិនឲ្យយកទៅលាយនឹងរបស់ដែលជាយាវកាលិកហើយឆាន់ឡើយ បើភិក្ខុប្រព្រឹត្តល្មើស ត្រូវអាបត្តិបាចិត្តិយ ។

សូមបញ្ជាក់ថា កាលិកទាំង ៤ នេះបាត់ចូលក្នុងលហុភណ្ឌ ភិក្ខុអាចចែកគ្នាឆាន់បានឥតមានទោសអ្វីឡើយ ។ ភិក្ខុអ្នកទទួលនូវភណ្ឌទេយ្យ ត្រូវទទួលសងវិញ ។

៥. អាការៈដែលមិនត្រូវអាបត្តិមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ? ចូរពោលឲ្យច្បាស់លាស់មកមើល ?

ឆ. អាការៈដែលមិនត្រូវអាបត្តិមាន ៦ យ៉ាងគឺ :

១– អលជ្ជិតា ត្រូវដោយឥតខ្មាស់ ។

២– អញ្ញាណតា ត្រូវដោយមិនដឹង ឬ មិនស្គាល់ ។

៣– កុក្កុច្ចបកតត្តា ត្រូវដោយសង្ស័យ ហើយពេះតែធ្វើ ។

៤ អកប្បិយេ កប្បិយសញ្ញិតា ត្រូវដោយសំគាល់ថា មិនគួរក្នុងរបស់ដែលគួរ ។

៥– កប្បិយេ អកប្បិយសញ្ញិតា ត្រូវដោយសំគាល់ថាគួរក្នុងរបស់ដែលមិនគួរ ។

៦– សតិសម្មោសា ត្រូវដោយភ្លេចស្មារតី ។

ជ. ពាក្យថា បព្វជ្ជា និង ឧបសម្បទា ក្នុងកាលឥឡូវនេះផ្សេងគ្នាយ៉ាងណា ? បុគ្គលដូចម្តេចខ្លះដែលត្រូវហាម បព្វជ្ជា និង ឧបសម្បទាជាដាច់ខាតនោះ ?

ង. ការបួសជាសាមណេរ ដោយការទទួលត្រៃសរណគមន៍ ហៅថា « បព្វជ្ជា », ការបួសជាភិក្ខុដោយការសម្រេចញត្តិចតុត្ថកម្មនោះ លោកហៅថា « ឧបសម្បទា » ។

បុគ្គល ១២ ជំពូកដែលហាមមិនឲ្យបព្វជ្ជា ឬ ឧបសម្បទា ៗ ១ បណ្ឌក, ២ ឧភតោព្យញ្ជនៈ, ៣ តិរច្ឆាន, ៤ ស្រី, ៥ បុគ្គលប្រទូស្តនឹងភិក្ខុនី, ៦ បុគ្គលក្លែងខ្លួនជាភិក្ខុ, ៧ បុគ្គលបួស-សាសនាអន្យតិត្ថិយហើយទាំងខេជាភិក្ខុ, ៨ បុគ្គលធ្វើមាតុឃាត, ៩ បិតុឃាត ១០ អរហន្តឃាត, ១១ លោហិតុប្បាទ, ១២ភិក្ខុធ្វើសង្ឃភេទ ។

ទាំង ១២ ពួកនេះ អភព្វបុគ្គលហាមមិនឲ្យបួសជាសាម-ណេរ ឬ ភិក្ខុបានឡើយ ។

ច. ព្រះវិន័យ មានផ្លូវរក្សាតែកាយនិងវាចាឲ្យរាបសា ប៉ុណ្ណោះ មិនមាននិយាយទាក់ទងដល់ផ្លូវចិត្តផងទេ, ចុះហេតុអ្វីក៏មានសិក្ខាបទខ្លះជាប់ទាក់ទងដោយផ្លូវចិត្តផង ?

ឆ. ព្រះវិន័យគ្មាននិយាយដាច់ដល់ផ្លូវចិត្ត ដែលប្រព្រឹត្ត កន្លងនូវសិក្ខាបទចំពោះតែផ្លូវចិត្តសុទ្ធក៏ពិតមែនហើយ តែបើទុក ជាដូច្នោះក៏ដោយក៏នៅតែមានសិក្ខាបទខ្លះដែលនិយាយដាច់ទាក់ ទងដល់ផ្លូវចិត្តផងដែរ ព្រោះចិត្តជាប្រធានរបស់កាយ និង វាចា បើចិត្តជឿនការពិត តាមធម្មតានិយមគប់បង្គំដោយបរិសុទ្ធស្អាតស្អំ ហើយ ក៏យឹតយោងនាំកាយ និង វាចាឲ្យធ្វើឲ្យនិយាយតែខាង ល្អ, បើចិត្តអាក្រក់សៅហ្មងហើយ ក៏ដឹកនាំកាយវាចាឲ្យធ្វើឲ្យ និយាយតែខាងផ្លូវលាមក ។

ដោយហេតុនេះហើយ ទើបវិន័យមាននិយាយដាច់ទាក់ ទងដោយផ្លូវចិត្តផងដែរនោះ ។

ស. ដូចម្តេចហៅថា សមុដ្ឋាន ? មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. ដែលហៅថា សមុដ្ឋាន វិធីបានដល់ទីតាំងនៃអាបត្តិ នានា មាន ៦ យ៉ាងគឺ:

១ កាយ, ២- វាចា, ៣- កាយវាចា, ៤ កាយចិត្ត, ៥ វាចាចិត្ត, ៦- កាយវាចាចិត្ត ។

អាបត្តិទាំងឡាយកើតឡើងដោយសមុដ្ឋានមួយខ្លះ, ពីរខ្លះ, បីខ្លះ, បួនខ្លះ, ប្រាំមួយខ្លះ ។ អាបត្តិដែលកើតឡើងដោយសមុដ្ឋាន ៥ មិនមានឡើយ ។

អាបត្តិកើតឡើងដោយសមុដ្ឋាន ១ រមែងកើតដោយសមុដ្ឋានទី៤ ខ្លះទី ៥ ខ្លះទី ៦ ខ្លះ មិនកើតដោយសមុដ្ឋានឯទៀតទេ ។ អាបត្តិដែលកើតឡើងដោយសមុដ្ឋាន ២ រមែងកើតដោយសមុដ្ឋានទី ១ និងទី ៤ ខ្លះ, ទី ២ និងទី ៥ ខ្លះ, ទី ៣ និង ទី ៦ ខ្លះ, ទី ៤ និង ទី ៦ ខ្លះ, ទី ៥ និង ទី ៦ ខ្លះ ។

អាបត្តិដែលកើតឡើងដោយសមុដ្ឋាន ៣ រមែងកើតដោយសមុដ្ឋាន ៣ ខាងដើមខ្លះ, ៣ ខាងចុងខ្លះ ។

អាបត្តិដែលមានសមុដ្ឋាន ៤ រមែងកើតដោយសមុដ្ឋានទី ១ ទី ៣ ទី ៤ និង ទី ៦ ខ្លះ, ដោយសមុដ្ឋានទី ២ ទី ៣ ទី៥ និង ទី ៦ ខ្លះ ។

អាបត្តិដែលមានសមុដ្ឋាន ៦ រមែងកើតឡើងដោយ

សមុដ្ឋានទាំង ៦ តែម្តង ។ ដើម្បីជាការងាយទន្ទេញឲ្យចាំមាត់ លោកបានចងទុកជាគាថាព័ន្ធដូចខាងក្រោមនេះ ៖

តិធា ឯកសមុដ្ឋានា បញ្ចធា ទ្វិសមុដ្ឋានតោ
ទ្វិធា តិចតុរុដ្ឋានា ឯកធា ឆសមុដ្ឋិតា ។

ប្រែ: អាបត្តិកើតដោយសមុដ្ឋាន ១ មាន ៣ ពួក ។. កើតដោយសមុដ្ឋាន ២ មាន ៥ ពួក, កើតដោយសមុដ្ឋាន ៣ និងសមុដ្ឋាន ៤ មាន ២ ពួក ។ អាបត្តិដែលកើតឡើងដោយសមុដ្ឋាន ៦ មានតែមួយពួក ។

ស. ព្រះធម៌និងវិន័យហាក់ដូចជាសភាវៈគួរផ្ទឹមគ្នាបាន គេចង់ដឹងថា តើសភាវៈណាចាស់ជាងសភាវៈណា ? ហើយវៀងពីគ្នាយ៉ាងណា ? ចូរដោះស្រាយ ។

ឆ, ធម៌ជាសភាវៈកើតមុន វិន័យជាសភាវៈកើតឡើងក្នុងពេលមានភិក្ខុសង្ឃកើតមានច្រើន ក្នុងព្រះពុទ្ធសាសនា ។

ហេតុនេះធម៌ជាសភាវៈចាស់ជាងព្រះវិន័យ ។

ធម៌ជាទុកខដែលព្រះពុទ្ធអង្គទ្រង់សំដែង ខាងសេចក្តីប្រតិបត្តិ សម្រាប់ពន្យល់សេចក្តីប្រព្រឹត្តិ និងធ្វើអធ្យាស្រ័យឲ្យល្អប្រពៃឡើង ។ ធម៌នោះឲ្យគុណនិងផាក់ទោស ដល់អ្នកប្រតិបត្តិល្អ និងអាក្រក់សមគួរតាមយថាហេតុ ចំណែកខាងព្រះវិន័យ ជាពុទ្ធបញ្ញត្តិដែលព្រះអង្គទ្រង់តាំងឡើងជាពុទ្ធអាណា ជាទីព្រហ្មចារ្យ និងអភិសមាចារ្យដើម្បីនាំសេចក្តីប្រតិបត្តិឲ្យមានរបៀបត្រឹមត្រូវស្មើគ្នាល្អ ជាច្បាប់សម្រាប់រក្សាអ្នកបួសឲ្យតាំងនៅដោយសុខសួស្តី ។

៥៦. អ្វីហៅជា សិក្ខាបទ ? ព្រោះហេតុអ្វីបានជាហៅដូច្នេះ

ឆ. មូលបញ្ញត្តិ គឺសេចក្តីហាមប្រាម ដែលទ្រង់តាំងទុកជាលើកដំបូង និងអនុប្បញ្ញត្តិ គឺសេចក្តីហាមដែលទ្រង់បន្ថែមជាខាងក្រោយរួមទាំងពីរយ៉ាងនេះហៅជាសិក្ខាបទ ព្រោះជាផ្លូវជាកន្លែងដែលអ្នកបួសត្រូវសិក្សារៀនសូត្រ ។

៥៧- ការទទួលប្រគេន មានច្បាប់កំណត់យ៉ាងណាខ្លះ? ដែលភិក្ខុសាមណេរគួរទទួលបាន ។

ឆ. មានកំណត់ដោយអង្គ ៥ យ៉ាងគឺ៖

១- របស់ដែលត្រូវប្រគេននោះ មិនធ្ងន់មិនធំហួសពេក ល្មមមនុស្សយ៉ាងមធ្យមលើកម្នាក់ឯងបាន ។

២ - អ្នកប្រគេនចូលមកក្នុងហត្ថបាសគឺឃ្លាត ២ ហត្ថមួយចំអាមចូលមក ។

៣ ទាយកបង្អោនទេយ្យវត្ថុចូលមក ។

៤ - ទាយកប្រគេនផ្ទាល់នឹងកាយ ។

៥ ភិក្ខុទទួលផ្ទាល់នឹងកាយឬដោយរបស់ជាប់នឹងកាយ ។ បើកាលណាការទទួលប្រគេនត្រូវច្បាប់ទាំង ៥ ខាងលើនេះហើយ នោះទើបភិក្ខុសាមណេរអាចបរិភោគប្រើប្រាស់របស់នោះបាន ។

## ប្រស្នាទី ៤

ស ពាក្យថា វិន័យបានដល់សភាវៈអ្វីទៅ ? មានអ្នកខ្លះគ្រាន់តែឮថាវិន័យ ៗ ប៉ុណ្ណោះក៏ធុញទ្រាន់ទៅហើយ តើវិន័យនោះមានប្រយោជន៍អ្វី ?

ឆ . បានដល់កិរិយាដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ហាមប្រាម

និងកិរិយាដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាត ។ មានប្រយោជន៍យ៉ាងនេះគឺ ព្រះវិន័យជាច្បាប់សម្រាប់ភិក្ខុសង្ឃឲ្យស្ថិតនៅដោយល្អ ៗ ដូចជាអំបោះសម្រាប់ចងក្រងផ្កាឲ្យមានរបៀបល្អកុំឲ្យខ្ចាត់ខ្ចាយរាត់រាយ វិន័យជាគ្រឿងការពារសេចក្ដីប្រព្រឹត្តអាក្រក់ ដឹកនាំឲ្យប្រព្រឹត្តល្អ, ឲ្យកើតសទ្ធាជ្រះថ្លា ។ ធម្មតាមនុស្សដែលរស់នៅច្រើនគ្នា រមែងមានអធ្យាស្រ័យផ្សេង ៗ ពីគ្នា, មានកម្លាំងមិនស្មើគ្នា អ្នកដែលមានអធ្យាស្រ័យអាក្រក់និងកម្លាំងច្រើនក៏នឹងកំហែងអ្នកដែលមានកម្លាំងតិច. ហេតុនោះបានជាម្ចាស់ផែនដីទ្រង់តាំងច្បាប់សម្រាប់ប្រទេសជាតិ ដើម្បីហាមប្រាមមនុស្សដែលប្រព្រឹត្តខុស ដាក់ទោសដល់មនុស្សដែលប្រព្រឹត្តល្មើសកន្លងនឹងរាជបញ្ញត្តិ, សូម្បីក្នុងគ្រួសារមួយ ៗ ឬនិគមមួយ ៗ ក៏គង់មានច្បាប់សម្រាប់គ្រួសារដើម្បីបង្ការសេចក្ដីខូចទិងយឺតយោងនាំឲ្យ មានប្រព្រឹត្តជារបៀប រៀប សារល្អដែរ ។ បើក្នុងពួកភិក្ខុមិនមានព្រះវិន័យ ជាគ្រឿងឃុំគ្រងហើយ ប្រហែល

គ្មាននឹងផ្កាឈើ ដែលគេដាក់គរ ជាគំនរនៅក្នុងទីវាល មិនមានខ្សែអំបោះចងត្បូងទុកទេ បើកាលណាត្រូវខ្យល់បក់បោកមកនឹងប៉ុនឹងខ្ចាត់ខ្ចាយតាំងនៅមិនបាន ។ ព្រះវិន័យរមែងរក្សាពួកភិក្ខុឲ្យតាំងនៅដោយល្អ ដូចអធិប្បាយមកខាងលើនេះ ។

ម្យ៉ាងទៀតកុលបុត្រ ដែលចូលមកបួសក្នុងព្រះពុទ្ធសាសនា មានវណ្ណៈផ្សេង ៗ ពីគ្នា គឺមកពីត្រកូលអ្នកមានក៏មានអ្នកក្រក៏មាន ហើយមានបរិយាផ្សេង ៗ ពីគ្នាផងដែរ ថែមទាំងគំនិតក៏ផ្សេងគ្នាដែរ, ប្រសិនបើគ្មានព្រះវិន័យគ្រប់គ្រងទេ ឬមិនប្រព្រឹត្តតាមព្រះវិន័យទេ, គង់នឹងក្លាយទៅជាពួកភិក្ខុអាក្រក់ឥតមានរបៀប មិនជាទីតាំងនៅនៃសទ្ធាជ្រះថ្លា ។ បើនាំគ្នាប្រព្រឹត្តតាមវិន័យហើយ នឹងបានជាពួកភិក្ខុត្រឹមត្រូវល្អ ដូចផ្កាឈើដែលមានពណ៌ផ្សេង ៗ ពីគ្នា គឺល្អខ្លះមិនសូវល្អខ្លះ បើនាយមាលាការប៉ិនប្រសប់ចាត់ឲ្យត្រូវតាមរបៀប តកល់ទុកលើជើងពាន ហើយក៏ត្រឡប់ទៅជារបស់គួរទស្សនាបាន, ព្រះវិន័យមានប្រយោជន៍ច្រើនប្រការ បានជាគេចូលចិត្តប្រតិបត្តិតាម ។

ស. ពាក្យថាសទ្ធិវិហារិកនិងអន្តេវាសិកមានសេចក្តីប្លែកគ្នាយ៉ាងណា ? សទ្ធិវិហារិកជាសិស្សរបស់អ្នកណា ?

ឆ. ពាក្យថាសទ្ធិវិហារិកនិងអន្តេវាសិក . មានសេចក្តីប្លែកគ្នាយ៉ាងនេះ សទ្ធិវិហារិកបានដល់ភិក្ខុសាមណេរដែលជាសិស្សផ្ទាល់របស់ព្រះឧបជ្ឈាយ៍ ត្រូវនៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ឲ្យលោកមើលការខុសត្រូវស្តីប្រដៅជានិច្ច ។ រីឯអន្តេវាសិកវិញ ឬ អន្តេវាសីបានដល់ភិក្ខុសាមណេរ ដែលគ្រាន់តែនៅសំណាក់ឬក្នុងទីជិតគ្រូអាចារ្យ ។ សទ្ធិវិហារិកជាសិស្សនៅក្នុងសំណាក់គ្រូផ្ទាល់ ។ ឯអន្តេវាសិកជាសិស្សអាចារ្យ ។

ស. ចុះអន្តេវាសិកមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. អន្តេវាសិកមាន ៤ គឺ :

១ បព្វជ្ជន្តេវាសិក សិស្សបំបួសឲ្យបានជាសាមណេរ

២–ឧបសម្បទន្តេវាសិក សិស្សសូត្រឲ្យបានជាភិក្ខុ ។

៣–និស្សយន្តេវាសិក សិស្សឲ្យនិស្ស័យ ។

៤- ឧទ្ទេស្សន្តេវាសិក សិស្សរៀនបាលី ។

៥-ធម្មន្តេវាសិក សិស្សរៀនធម៌គាថាឬរៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេង ៗ ។

ស. អាចារ្យមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ. អាចារ្យមាន ៥ យ៉ាងគឺ :

១- បព្វជ្ជាចារ្យ អាចារ្យបំបួសជាសាមណេរ ។

២- ឧបសម្បទាចារ្យ អាចារ្យសូត្រឲ្យឡើងជាភិក្ខុ ។

៣- ឧទ្ទេសាចារ្យ អាចារ្យបង្រៀនបាលី ។

៤- និស្សយាចារ្យ អាចារ្យឲ្យនិស្ស័យ ។

៥- ធម្មាចារ្យ អាចារ្យបង្រៀនធម៌ ។

ស- សមណៈត្រូវប្រកបដោយអង្គប៉ុន្មាន គឺអ្វីខ្លះ ?

ឆ- សមណៈត្រូវប្រកបដោយអង្គ ៤ យ៉ាងគឺ :

១-ខន្តិ ត្រូវមានសេចក្តីអត់ធន់ ។

២ អប្បមាទេ៎ា ត្រូវកុំប្រហែសធ្វេសក្នុងកុសលធម៌ ។

៣- រតិបហាន ការលះបង់នូវសេចក្ដីត្រេកអរក្នុងវត្ថុកាមនិងកិលេសកាម ។

៤- អកិញ្ចនំ ឥតមានខ្វល់ខ្វាយក្នុងកិច្ចដែលឥតប្រយោជន៍ ។

ស ភិក្ខុមិនដឹង ហើយឲ្យឧបសម្បទាដល់កុលបុត្រដែលមានអាយុមិនគ្រប់ ២០ ឆ្នាំ តាំងកុលបុត្រនោះ ក៏នឹកស្មានថាខ្លួនមានអាយុគ្រប់ ២០ ឆ្នាំហើយដែរ , តើភិក្ខុអ្នកបំបួសត្រូវមានទោសអ្វីដែរឬទេ ? ហើយកុលបុត្រនោះទៀតឡើងជាភិក្ខុឬទេ ?

ឆ. ភិក្ខុអ្នកបំបួសឥតត្រូវទោសអ្វីទេ , ឯកុលបុត្រនោះពុំបានឡើងជាភិក្ខុភាវៈពេញទីទេ ។

ស. តាមផ្លូវព្រះវិន័យប្រាកដក្ដីមាសក្ដី ឬវត្ថុណាមួយដែលគេសន្មតសម្រាប់ចាយ មានច្បាប់ហាមមិនឲ្យភិក្ខុសាមណេររើស

របស់នោះទេ ។ ស. ជួនជាគេនិមន្តគេក្បួននៅក្នុងកន្លែងណាមួយ បើភិក្ខុសាមណេររើសត្រូវទោស ។ ចង់ដឹងថាតើភិក្ខុសាមណេរនោះ ៗ អាចរើសខ្លួនវត្ថុទាំងនោះយកមកទុកបានដែរឬទេ ?

ឆ. ភិក្ខុសាមណេរអាចរើសរបស់ទាំងនោះយកមកទុកបាន ប៉ុន្តែរើសបានតែវត្ថុណាដែលជ្រុះនៅក្នុងវត្ត សិងមានព្រះអានន្ទត្ថេរ ដែលបានរើសគ្រឿងឧបភោគៈរបស់នាងវិសាខាជា និងទស្សន៍ស្រាប់ ។

ស. នៅក្នុងសេក្ខិយវត្តទាំង ៧៥ សិក្ខាបទ ចែកជាប៉ុន្មានពួក ? អ្វីខ្លះ ? ពួកនិមួយ ៗ មានសិក្ខាបទប៉ុន្មាន ?

ឆ. ក្នុងសេក្ខិយវត្តទាំង ៧៥ សិក្ខាបទនេះចែកចេញជា ៤ ពួកគឺ ៖

ពួកទី ១ ឈ្មោះសារុប្ប មានសិក្ខាបទ ២៦ ។

ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត មានសិក្ខាបទ ៣០ ។

ពួកទី ៣ ឈ្មោះធម្មទេសនាបដិសំយុត្តមានសិក្ខាបទ ១៦ ។

ពួកទី ៤ ឈ្មោះ បកិណ្ណកៈ មានសិក្ខាបទ ៣ រួមទាំងអស់ត្រូវជា ៧៥ សិក្ខាបទ ។

ស. អាបត្តិដូចម្ដេចជាសតេកិច្ឆា ? ដូចម្ដេចជាអតេកិច្ឆា ? ពាក្យថាសតេកិច្ឆា និង អតេកិច្ឆានេះបានសេចក្ដីថា ដូចម្ដេចទៅ? សូមពន្យល់មកមើល ?

ឆ. អាបត្តិដែលភិក្ខុត្រូវហើយអាចធ្វើខ្លួនឲ្យបរិសុទ្ធវិញបាន ដោយវិធីណាមួយមានការសំដែងចេញជាដើម (ដែលជាទេសនាសុទ្ធិ) តាមគួរដល់អាបត្តិហៅថាសតេកិច្ឆា (គឺកែខ្លួនបានឡើងវិញ ។ អាបត្តិដែលភិក្ខុត្រូវហើយ មិនអាចកែខ្លួនបានវិញ គឺធ្វើខ្លួនឲ្យបរិសុទ្ធវិញមិនបានហៅថា អតេកិច្ឆា (មានអាបត្តិបារាជិកជាដើម ។

ស. អាបត្តិទាំងពីរពួកនេះមានដំបច្រើនជាងគ្នាប៉ុន្មាន ? ណាខ្លះជាសតេកិច្ឆា ដែលភិក្ខុត្រូវហើយ ត្រូវតោលទោសក្នុងសំណាក់សង្ឃ , គណៈ , បុគ្គល ?

ឆ. អាបត្តិទាំងពីរពួកនេះមានតិចច្រើនជាងគ្នាយ៉ាងនេះគឺ ៖ អតេកិច្ឆាបានដល់អាបត្តិ ១ កង គឺ បារាជិក ៤ ។

ចំណែកសតេកិច្ឆាបានដល់អាបត្តិ ៦ កង គឺសង្ឃាទិសេស បាចិត្តិយ, ទុក្កដជាដើម ។ អាបត្តិសង្ឃាទិសេសបើភិក្ខុត្រូវហើយ ត្រូវពោលទោសដោយជំនុំសង្ឃ ។ ឯអាបត្តិ៥កងទៀត ត្រូវពោលទោសដោយគណៈឬបុគ្គលក៏បាន ។

ជ. ភិក្ខុត្រូវអាបត្តិអតេកិច្ឆា ត្រូវដាច់ចាកជាភិក្ខុភាព ឈ្មោះថាដាច់សិក្ខាជាភិក្ខុហើយ លុះត្រឡប់ទៅជាគ្រហស្ថវិញ, ក៏ដឹងថា បើថ្ងៃក្រោយអ្នកនោះចូលមកសូមខមាទោសនឹងសង្ឃ ហើយសូមបួសវិញ តើសង្ឃអាចលុបលាងទោសនោះឲ្យបព្វជាឧបសម្បទាជាភិក្ខុវិញបានឬទេ ? ព្រោះហេតុអ្វី ? សូមឆ្លើយជាមួយនឹងការវិនិច្ឆ័យជាមុន ។

ឈ. ភិក្ខុត្រូវអតេកិច្ឆា ត្រូវដាច់ចាកជាភិក្ខុភាពហើយសូមចូលមកខមាទោសនឹងសង្ឃវិញ ដើម្បីសូមឧបសម្បទាជាភិក្ខុ

សង្ឃមិនអាចបំបួសវិញបានទេ ពីព្រោះអតេកិច្ឆាបត្តិនេះ គឺបាន ដល់អាបត្តិបារាជិកទាំង ៤ អាបត្តិនេះបើភិក្ខុត្រូវហើយ ប្រៀបដូច ស្លឹកឈើទុំដែលជ្រុះចាកទង មិនអាចយកទៅភ្ជាប់វិញបានទេ ក៏ មានឧបមេយ្យដូច្នោះទេ ។ តែបើសូមបព្វជាជាសាមណេរវិញ បានឥតមានហាមឃាត់ឡើយ ។ ចំណែកបួសជាភិក្ខុមិនបានជា ដាច់ខាត ។

ស. ភិក្ខុមិនមានសទ្ធា ហើយអួតខ្លួនជាមានសទ្ធា តើ កាត់ឲ្យត្រូវអាបត្តិអ្វី ? ព្រោះហេតុអ្វី?

ឆ. ភិក្ខុមិនមានសទ្ធាហើយអួតថាមានសទ្ធា ត្រូវអាបត្តិ ថុល្លច្ច័យ ពីព្រោះការអួតអាងនេះជាមន្ទិល មិនមែនជាលក្ខណៈ របស់មនុស្សល្អទេ ព្រោះព្រះពុទ្ធសាសនាសំដៅយកសេចក្តីបរិ- សុទ្ធិ ពុំមែនយកការអួតអាងជាសេចក្តីបរិសុទ្ធបុត្រឹមត្រូវឡើយ ។

ស. មាតុគ្រាមដែលជាវត្ថុនៃសង្ឃាទិសេស ក្នុងសិក្ខា បទទី ២ និងទី ៣ សំដៅយកសេចក្តីផ្សេងគ្នាឬដូចគ្នាយ៉ាងណា

ចូរដោះស្រាយ ។

ឆ. សំដៅយកសេចក្ដីផ្សេងគ្នាយ៉ាងនេះគឺ ៖

សិក្ខាបទទី ២ គឺកាយសំសគ្គៈភិក្ខុមានតម្រេកចាប់ពាល់ត្រូវកាយស្ត្រី ត្រូវអាបត្តិសង្ឃាទិសេស ។ ចំណែកឯសិក្ខាបទទី៣ គឺទុដ្ឋុល្លវាចាភិក្ខុមានតម្រេកនិយាយពាក្យអាក្រក់ចំពោះខមិត្ត ស្ត្រី ត្រូវសង្ឃាទិសេស ។

ស. សិក្ខាបទទី ៦ នៃសង្ឃាទិសេស ដូចម្ដេចដែលភិក្ខុត្រូវព្រោះមិនធ្វើ ? – ដូចម្ដេចដែលត្រូវព្រោះធ្វើ ? គឺធ្វើអ្វី ?

ឆ. សិក្ខាបទទី ៦ នៃសង្ឃាទិសេសនេះ ដែលត្រូវព្រោះធ្វើនោះ គឺធ្វើកុដិឲ្យធំហួសប្រមាណ ហើយដែលត្រូវព្រោះមិនធ្វើនោះ គឺមិនបានឲ្យសង្ឃសំដែងទីឲ្យជាមុនសិន ។ នេះជាសេចក្ដីបរិយាយអំពីសិក្ខាបទទី ៦ នេះ ។

ស. ដូចម្ដេចដែលហៅថា អាបត្តិមិនមានមូល ? អ្វីខ្លះ ? ចាត់ជាមូល ? ភិក្ខុចោទប្រកាន់ភិក្ខុដទៃមិនមានមូលតើត្រូវអាបត្តិអ្វី ? ចូរដោះស្រាយ ។

ឆ. ដែលហៅថាអាបត្តិមិនមានមូលនោះគឺ :

បានដល់អាការៈ ៣ យ៉ាងគឺមិនដឹង ១, មិនឃើញ ១, មិនឮ ១, បេះតែចោទដោយស្អប់គ្នា ៗ ទាំង ៣ នេះ ចាត់ជាមូលរបស់អាបត្តិ ៗ ចំពោះភិក្ខុដែលចោទប្រកាន់ភិក្ខុដទៃមិនមានមូលនេះ អាចបែកជាពីរផ្នែកគឺ . បើភិក្ខុអ្នកចោទចំពោះអាបត្តិបារាជិក, អ្នកចោទត្រូវអាបត្តិសង្ឃាទិសេស ៗ តែបើភិក្ខុអ្នកចោទបានចោទចំពោះអាបត្តិសង្ឃាទិសេស, ភិក្ខុអ្នកចោទត្រូវអាបត្តិបាចិត្តិយ ៗ

ស. ក្នុងសង្ឃាទិសេសទាំង ១៣ នោះ តើខណាខ្លះដែលភិក្ខុត្រូវក្នុងខណ ដែលសង្ឃសូត្រសមនុភាសនកម្មចប់ ?

ឆ. ក្នុងសង្ឃាទិសេសទាំង ១៣ នោះ មានតែ ៤ សិក្ខាបទទេ ដែលភិក្ខុត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ គឺសិក្ខាបទទី ១០, ១១, ១២ និង ១៣ ៗ

ស. ភិក្ខុធ្វើយ៉ាងណាហៅថាទ្រុស្តត្រកូល ហើយត្រូវអាបត្តិអ្វី ?

ឆ. គឺភិក្ខុដែលធ្វើការប្រចុបប្រចែងគ្រហស្ថ សង្ឃ បាន

បណ្ដេញចេញពីវត្ត ហើយត្រឡប់តិររៀលសង្ឃវិញ ធ្វើបែបនេះហៅថាភិក្ខុទ្រុស្តត្រកូល ។

ស. ពាក្យថា អព្ភានកម្មនេះ តើត្រូវធ្វើដោយប្រជុំភិក្ខុប៉ុន្មានរូប ? ចំពោះរឿងអ្វី ? ក្នុងទីដូចម្ដេច ?

ឆ. ពាក្យថា អព្ភានកម្មនេះ ជាកម្មដែលសង្ឃគប្បីក្រាប្រណីហៅគេវិញ ហៅថា អព្ភានកម្ម, ត្រូវធ្វើដោយប្រជុំភិក្ខុតាំងពី ២០ រូបឡើងទៅ ។ ព្រោះព្រួចចំពោះរឿងដែលភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងទីដែលមានសីមាត្រឹមត្រូវ ។

ស. សង្ឃកម្មក្នុងសាសនាមានច្រើន បើចែកជាពួកមានប៉ុន្មានពួក ? គឺអ្វីខ្លះ?

ឆ. សង្ឃកម្មក្នុងសាសនាមានច្រើនពួកមែន តែបើចែកជាពួកមាន ៤ ប៉ុណ្ណោះគឺ ៖

អបលោកនកម្ម១, ញត្តិកម្ម១, ញត្តិទុតិយកម្ម១, និងញត្តិចតុត្ថកម្ម ១

ស. ពាក្យថា អបលោកនកម្ម បានសេចក្ដីថាដូចម្ដេច ?

មានប៉ុន្មានសណ្ឋាន ? គឺអ្វីខ្លះ ? ការធ្វើព្រហ្មទណ្ឌដល់ភិក្ខុរឹងរូសប្រដៅមិនបាន និងការបណ្ដេញសាមណេរត្រូវនាសនង្គៈ ចាត់ចូលក្នុងកម្មណា ?

ឆ- អបលោកនកម្មបានសេចក្ដីថា កម្មដែលគេប្រកាសប្រាប់គ្នាឲ្យបានដឹងដោយមិនបាច់តាំងញត្តិហៅថាអបលោកនកម្ម មាន ៥ យ៉ាង គឺ :

១-និសារណា ការបណ្ដេញសាមណេរ ដែលត្រូវនាសនង្គៈ ព្រោះពោលតិះដៀលព្រះពុទ្ធ ចេញពីពួកគណៈ ដូចក្នុងសិក្ខាបទទី១០ នៃសប្បាណកវគ្គក្នុងបាចិត្តិយកណ្ឌ ។

២-ឱសារណា ការអត់ទុន ឬ សាមណេរដែលនោះ ត្រឡប់ប្រព្រឹត្តល្អឡើងវិញ ឲ្យចូលក្នុងពួកនោះវិញ ។

៣-ភណ្ឌុកម្ម ការប្រកាសប្រាប់នូវការសុំអនុញ្ញាតកោរសក់ដល់អ្នកដែលចូលបួស ដែលភិក្ខុត្រូវធ្វើត្រូវកោរឲ្យ ។

៤-ព្រហ្មទណ្ឌ ការប្រកាសព្រហ្មទណ្ឌ គឺហាមប្រាម

មិនឲ្យនិយាយកេកភិក្ខុដែលរឹងត្អឹងជាអ្នកប្រដៅក្រ ដូចកាលដែលធ្វើដល់ព្រះឆន្នត្ថេរ ក្រោយពេលដែលព្រះអង្គបរិនិព្វានហើយ ។

៥ – កម្មលក្ខណៈ បានដល់កម្មដែលភិក្ខុនីសង្ឃប្រកាសហាមប្រាមគ្នាមិនឲ្យសំពះចំពោះភិក្ខុ ដែលសំដែងសេចក្តីរំលោភដ៏មិនសមរម្យដល់ពួកភិក្ខុនីសង្ឃ ។

ការអបលោកន៍ក្នុងការចែកអាហារក្នុងវេលាឆាន់ ការអបលោកន៍ឲ្យចីវរ និងរបស់ផ្សេងៗ ។ ក្នុងពេលឥឡូវនេះមានប្រើច្រើនតែក្នុងការអបលោកន៍ ឲ្យសំពត់កឋិនដល់ភិក្ខុអ្នកទទួលក្រាលគ្រងកឋិន ការចែកចីវរដល់អាគន្តុកៈក្នុងចីវរកាល ការចែកអាហារមិនស្មើគ្នា ។

ការធ្វើព្រហ្មទណ្ឌដល់ភិក្ខុប្រព្រឹត្តរឹងរូស និងការបណ្តេញសាមណេរត្រូវនាសនង្គៈ ចាត់ចូលក្នុងញត្តិចតុត្ថកម្ម ។

ស. ពាក្យថា ញត្តិកម្មបានសេចក្តីដូចម្តេច ? ការឲ្យបាត្រ និងចីវរជាដើម ជានិស្សគ្គិយទៅម្ចាស់ដើមវិញ និងការ

ក្រោសពន្យាពេលបវារណាចាត់ចូលក្នុងសង្ឃកម្មណា ?

ឆ. ពាក្យថាញត្តិកម្មបានសេចក្ដីថា: កម្មដែលសង្ឃធ្វើដោយពិធីតាំងញត្តិ ដើម្បីប្រកាសឲ្យសង្ឃបានដឹងជាមុនសិន មានការធ្វើឧបោសថកម្មជាដើម ហៅថាញត្តិកម្ម ។ ការឲ្យបាត្រ និង ចីវរជាដើម ដែលជានិស្សគ្គិយដល់ម្ចាស់ដើមវិញ និងការពន្យាពេលបវារណា ចាត់ចូលក្នុងញត្តិកម្ម ។

ស. ញត្តិទុតិយកម្ម មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ការធ្វើឧបោសថ និងបវារណា, សូត្រសន្មតសីមា និង ការឲ្យមត្តកចីវរ ដល់ភិក្ខុសាមណេរដែលទៅបំរើអ្នកជម្ងឺ ចាត់ចូលក្នុងសង្ឃកម្មណា ?

ឋ, ញត្តិទុតិយកម្មមាន ៧ យ៉ាងគឺ,

១- និស្សារណា ការប្រកាសរម្លាប់លប់លាងប្រណាម វឌ្ឍលិច្ឆវី ដែលប្រព្រឹត្តឲ្យទោសដល់ព្រះពុទ្ធសាសនា ។

២- ឱសារណា ការប្រកាសប្រណាមលប់លាងវឌ្ឍលិច្ឆវី

ដែលដឹងទោសខ្លួន ហើយត្រឡប់ប្រព្រឹត្តត្រឹមត្រូវវិញ ។

៣- សម្មុតិ ការសន្មតរឿងផ្សេង ៗ មានការសន្មតសីមា និងសន្មតភិក្ខុឲ្យជាមេភ្នាក់ងារធ្វើការសង្ឃជាដើម ។

៤- ទាន ការឲ្យរបស់ផ្សេង ៗ គឺឲ្យសំពត់កឋិន ឲ្យចីវរ របស់ភិក្ខុសាមណេរដែលបានអនិច្ចធម្មហើយដល់គិលានុបដ្ឋាក ។

៥- ឧទ្ទារ ការប្រកាសផលអានិសង្សកឋិនជាដើម ។

៦- ទេសនា សំដែងទីសម្រាប់សានុមតិឲ្យដល់ភិក្ខុ ។

៧- កម្មលក្ខណៈ ការរម្ងាប់អធិករណ៍ដោយតិណវត្ថា-រកវិន័យ ។

ការធ្វើឧបោសថ, បវារណា ចាត់ចូលក្នុងញត្តិកម្ម ។ ការសូត្រសន្មតសីមា ចាត់ចូលក្នុងញត្តិទុតិយកម្ម ។ ការឲ្យមត្តកចីវរដល់ភិក្ខុ ឬ សាមណេរជាគិលានុបដ្ឋាក ចាត់ចូលក្នុងអបលោកនកម្ម ។

សរ. ញត្តិចតុត្ថកម្មបានសេចក្តីជាដូចម្តេច ? មានវិធីធ្វើដូចម្តេចខ្លះ ? ការធ្វើបព្វាជនីយកម្មចំពោះភិក្ខុមានកំហុស, ការប្រគេនកឋិនចីវរទៅឲ្យភិក្ខុអ្នកក្រាលគ្រង, ការឲ្យបរិវាសកម្មដល់ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស និង ការសូត្រសន្មតភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ពួកភិក្ខុនី ចាត់ចូលក្នុងសង្ឃកម្មណា ?

ឆ. ញត្តិចតុត្ថកម្មបានសេចក្តីថា កម្មដែលមានញត្តិជាគម្រប់ ៤ ឬថាមានអនុស្សាវនា ៣ និងញត្តិ ១ ។ ការធ្វើបព្វាជនីយកម្ម ចំពោះភិក្ខុមានកំហុសចាត់ចូលក្នុងញត្តិចតុត្ថកម្ម ។ ការប្រគេនកឋិនចីវរចំពោះភិក្ខុអ្នកក្រាលគ្រង ចាត់ចូលក្នុងញត្តិទុតិយកម្ម ។ ការឲ្យបរិវាសកម្មដល់ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេស និងការសូត្រសន្មតឲ្យជាអ្នកឲ្យឱវាទភិក្ខុនី ចាត់ចូលក្នុងញត្តិចតុត្ថកម្ម ។

សរ. ការសេពគប់នូវបាបមិត្រ ព្រះសាស្តាទ្រង់ហាមបញ្ញត្តិក្នុងសិក្ខាបទណាខ្លះ ?

ឆ. ការសេពគប់នូវបាបមិត្រព្រះសាស្តាទ្រង់ហាមក្នុងសិក្ខាបទទី ១១, ទី៦, ទី ៩, ទី ១០, ក្នុងសង្ឃាទិសេសនៃសប្បាណកវគ្គក្នុងបាចិត្តិយកណ្ឌ ។

ស. ក្នុងសង្ឃាទិសេសទាំង ១៣ នោះ តើសិក្ខាបទ ណា មានទោសច្រើនជាងសិក្ខាបទឯទៀត ? ព្រោះហេតុអ្វី ?

ឆ នៅក្នុងសិក្ខាបទទាំង ១៣ នៃសង្ឃាទិសេសនេះមានតែសិក្ខាបទទី ១០ មួយទេ ដែលមានទោសច្រើនជាងគេជាងសិក្ខាបទឯទៀត ៗ ។ ពីព្រោះសិក្ខាបទនេះបើនិយាយតាមផ្លូវធម៌ធ្លាក់ទៅដល់អនន្តរិយកម្មដែលជាកម្មធ្ងន់បំផុត ។ សិក្ខាបទនោះមានឈ្មោះថាសង្ឃភេទ គឺការបំបែកសង្ឃឲ្យបែកចេញពីគ្នា ។

ស. កិច្ចឆាយប្ញូដៅបើមាននៅក្នុងពួកណា តែងតែធ្វើឲ្យពួកនោះមានសេចក្តីចំរើន ដោយហេតុនោះព្រះពុទ្ធទ្រង់បញ្ញត្តិច្បាប់ដើម្បីឲ្យសង្ឃធ្វើនិគ្គហកម្មដល់ភិក្ខុ ដែលប្រព្រឹត្តជាសត្រូវចំពោះកិច្ចល្អនោះតើមានដែរឬទេ? ចូរឆ្លើយតាមគោលបារិកមកផង

ឆ. ការធ្វើនិគ្គហកម្ម ដល់ភិក្ខុដែលជាសត្រូវដល់ធម៌វិន័យនោះ មានពិតប្រាកដមែន ដូចមាននៅក្នុងញត្តិចតុត្ថកម្មជាគោលតាក់ស្រាប់ ដែលមាននិយាយអំពីការធ្វើទោសចំពោះភិក្ខុដែលប្រព្រឹត្តខុសក្នុងគងអាបត្តិសង្ឃាទិសេស ។

ឈ. ក្នុងសង្ឃាទិសេសទាំង ១៣ នោះ តើសិក្ខាបទណាដែលភិក្ខុត្រូវអាបត្តិព្រោះរាគៈជាឫសគល់ ? សិក្ខាបទណាដែលភិក្ខុត្រូវព្រោះមានទោសៈជាឫសគល់ ?

ឆ. ក្នុងសង្ឃាទិសេសទាំង១៣នោះ មានតែសិក្ខាបទទី ២ គឺកាយសំសគ្គ : ភិក្ខុមានតម្រេកចាប់ពាល់ទៅកាយស្ត្រី ត្រូវសង្ឃាទិសេសព្រោះមានរាគៈជាឫសគល់ ។ ហើយនិងសិក្ខាបទទី ១០ គឺសង្ឃភេទភិក្ខុព្យាយាមបំបែកសង្ឃត្រូវអាបត្តិសង្ឃាទិសេសព្រោះមានទោសជាឫសគល់ ។

ឈ. ការចូលវស្សានិងការបវារណាចេញវស្សារាប់ចូលជាជាសង្ឃកម្មបានឬទេ ? បើបានគេត្រូវធ្វើដោយសង្ឃវគ្គណា ?

ឆ. រាប់ចូលថាជាសង្ឃកម្មបាន ត្រូវធ្វើដោយសង្ឃបញ្ចវគ្គ ។

ស. ភិក្ខុសឹងកំដរមាតាដែលមានធុរៈឈឺ ក្នុងទីប្រក់ទីបាំង ជាមួយគ្នាមួយខណៈប៉ុណ្ណោះ នឹងឲ្យលោកត្រូវអាបត្តិអ្វីដែរឬទេ ? ព្រោះហេតុអ្វី ?

ឆ. បើតាមយោបល់យើង ដែលទឹកសំដៅចំពោះទៅលើមាតា ជាអ្នកមានគុណធ្ងន់ណាស់នោះ គួរតែថា; "គ្មានត្រូវអាបត្តិអ្វីទេ" ប៉ុន្តែនឹងយល់យ៉ាងនេះមិនកើតទេ ពីព្រោះក្នុងសិក្ខាបទ មិនមានប្រាប់ថាឲ្យលើកលែងមាតាចេញទេ មាននិយាយត្រឹមតែមាតុគ្រាម ។ ព្រោះហេតុនោះបើជាវេលាយប់ត្រូវអាបត្តិបាចិត្តិយ ព្រោះកំហុសត្រង់សម្រេចសហសេយ្យកិច្ចជាមួយមាតុគ្រាម; បើវេលាថ្ងៃត្រូវអាបត្តិបាចិត្តិយ ព្រោះសឹងក្នុងទីប្រក់ទីបាំងជាមួយមាតុគ្រាម ។

ស. ភិក្ខុណាធ្វើម្រែគ្នា ត្រូវអាបត្តិដូចគ្នា, នឹងក្នុងសិក្ខាបទណាដែលត្រូវអាបត្តិធ្ងន់ស្រាលជាងគ្នា ?

ឆ ក្នុងសំវិធាវហារនៃអទិន្នាទានសិក្ខាបទដែលភិក្ខុបបួលគ្នាទៅលួចត្រូវអាបត្តិដូចគ្នា ។ ក្នុងសិក្ខាបទទី ៥ នៃសប្បាណកវគ្គ ដែលចែងពីពួកភិក្ខុឲ្យឧបសម្បទដល់កុលបុត្រ ដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ ពួកភិក្ខុដទៃទៀតត្រូវអាបត្តិទុក្កដ ។

ស. លោកពុទ្ធរក្ខិត ទៅយកព្រះពុទ្ធរូបមួយអង្គនៅក្នុងព្រះវិហារ យកមកធ្វើជារបស់ខ្លួនដោយមិនបានអនុញ្ញាតពីអ្នកណាមួយសោះ; ចំណែកឯលោកជាធម្មរក្ខិតដឹងដូច្នោះហើយ ក៏ទៅយកពុទ្ធរូបនោះមកទុកកន្លែងដើមវិញ តើលោកទាំងពីរអង្គនោះនឹងត្រូវមានអាបត្តិអ្វីទេ ?

ឆ. បើព្រះពុទ្ធរូបនោះ មានម្ចាស់គេហួងហែងរក្សាហើយ លោកពុទ្ធរក្ខិតទៅយកមកដោយថេយ្យចិត្ត ក៏ត្រូវអាបត្តិតាមតម្លៃនៃពុទ្ធរូបនោះ, បើគ្មានថេយ្យចិត្តទេ ដោយគិតថាជារបស់ស្រមាប់ព្រះពុទ្ធសាសនា អ្នកណាយកទៅបូជាក៏បាន បើគិត

យ៉ាងនេះត្រូវសងវិញ បើវិហារនោះគ្រាំគ្រាបែកបាក់ មិនមានអ្នកណាគេរក្សាទេ ក៏មិនត្រូវអាបត្តិអ្វីឡើយ ។

ស. ត្រៃសិក្ខានិងធម៌វិន័យ និងសាសនាតើផ្សេងគ្នាឬដូចគ្នា ?

ឆ. ផ្សេងគ្នាដោយវោហារហៅ តែជាសភាវៈដូចគ្នាដោយសេចក្តីគឺ ៖ សីលសិក្ខាចំណែកខាងការរក្សាកាយនិងវាចាបានខាងវិន័យ, ចិត្តសិក្ខានិងបញ្ញាសិក្ខា ដែលជាគ្រឿងប្រតិបត្តិផ្លូវចិត្តរួមចូលក្នុងធម៌ ។ ធម៌និងវិន័យនេះ ជាឱវាទនៃព្រះពុទ្ធជាម្ចាស់ ដូចគ្នារួមគ្នាមកហៅថាសាសនាដែលប្រែថាពាក្យប្រៀនប្រដៅ ។

ស. ភិក្ខុចាប់ពាល់ចាប់ត្រូវកាយស្ត្រីដោយខ្លួនឯង ត្រូវសង្ឃាទិសេសនោះក៏ពិតមែនហើយ ; តែបើមានអ្នកណាមួយមានអំណាចខ្លាំងជាងខ្លួនមកបង្ខំឲ្យចាប់កាយស្ត្រី ភិក្ខុនោះខ្លាចគេក៏ចាប់ទៅ តើត្រូវអាបត្តិអ្វីដែរ ?

ឆ. ទោះបើមានគេបង្ខំក៏ដោយ បើភិក្ខុនេះចាប់ពាល់ដោយ

មានតម្រេកត្រូវអាបត្តិសង្ឃាទិសេស ; តែបើគ្មានតម្រេកទេ ចាប់ពាល់ដោយខ្លាចគេ យ៉ាងនេះមិនគួរឲ្យលោកត្រូវអាបត្តិឡើយ ។

សួ. ហេតុអ្វីក៏ក្នុងបាតិមោក្ខលោកចែកបាចិត្តិយជាពីរផ្នែក តើមានគំនិតយ៉ាងណា ?

ឆ. ដោយមានគំនិតយ៉ាងនេះថា : ផ្នែកខាងដើម ៣០ សិក្ខាបទនោះ ជាប់ដោយនិស្សគ្គិយវត្ថុ គឺត្រូវឲ្យលះវត្ថុនោះៗ សិន ទើបសំដែងអាបត្តិនោះដាច់ , ផ្នែកខាងក្រោយ ៩២ សិក្ខាបទនោះមិនជាប់ដោយនិស្សគ្គិយវត្ថុផងទេ គឺត្រូវហើយសំដែងតែម្តង , លើកលែងតែសិក្ខាបទខ្លះដែលត្រូវឲ្យកាត់ឬរុះរើសិន ទើបសំដែងអាបត្តិដាច់, ដូចកាត់ជើងគ្រែដែលខ្ពស់ហួសប្រមាណជាដើម ។

ហេតុនេះហើយ បានជាលោកចែងជាពីរផ្នែកយ៉ាងនេះ ។

សួ. ភិក្ខុឃើញស្រាស្មានជាទឹក ហើយក៏ផឹកទៅ តើត្រូវអាបត្តិអ្វី ? ព្រោះហេតុអ្វី ?

ឆ  ត្រូវអាបត្តិបាចិត្តិយ  ព្រោះសិក្ខាបទនេះជាអចិត្តក : ទោះបីស្មានខុសក៏ដោយ ក៏ត្រូវដែរ ។

សៈ  ភិក្ខុ ១ រូបវេលាដែលខ្លួនឈឺបានផ្តាំនឹងភិក្ខុជាសម្លាញ់ថា : របស់របរខ្ញុំប្រដាប់ប្រដាខ្ញុំទាំងអស់នេះ បើខ្ញុំស្លាប់ទៅសូមលោកយកទាំងអស់ចុះ, លុះលោកនោះទទួលអនិច្ចធម្មទៅហើយ តើប្រដាប់នោះគួរដល់ភិក្ខុជាសម្លាប់ឬទេ ? ចូរដោះស្រាយ ។

ឆ  ការប្រគល់ឲ្យដោយវិធីផ្តាំទុកនេះ យកជាការប្រាកដមិនបានទេ លុះណាតែប្រគល់ឲ្យដាច់ខាត តាំងពីខ្លួនរស់នៅទើបបាន ។

បើប្រគល់ឲ្យដោយវិធីបែបនោះ  របស់ទាំងនោះនឹងក្លាយទៅជារបស់សង្ឃ , បើភិក្ខុជាសម្លាញ់នោះនៅតែរឹងរូសនឹងយកបានឈ្មោះថា  យករបស់សង្ឃពេញទី ។

សៈ  បើភិក្ខុនៅចាំវស្សាក្នុងអាវាសដែលមិនមានពុទ្ធសីមា លុះដល់ចេញវស្សាហើយ  មានទាយកនាំសំពត់កឋិនមកវេរប្រគេន, យ៉ាងនេះតើត្រូវប្រតិបត្តិដូចម្តេច ?

ឆ. បើអាវាសនេះគួរយកជាតាមវាសីបាន ផុតមានសេចក្តីរង្កៀសទេ, ត្រូវសូត្រញត្តិទុតិយកម្មវាចាប្រគល់សំពត់កឋិនឲ្យដល់ភិក្ខុ ១ រូបក្នុងទីអាវាសនោះបាន ។ ពុំនោះសោតបើមាននទី គឺស្ទឹងឬទន្លេជាដើមនៅជិតនោះ ត្រូវសម្មតិឧទកុក្ខេបកសីមា ហើយសូត្រកម្មវាចាប្រគល់សំពត់កឋិន ដល់ភិក្ខុ១ រូបក្នុងពេលនោះ រួចហើយយកសំពត់កឋិននោះមកក្រាលគ្រង អនុមោទនានៅទីដែលចាំវស្សាបាន ។ បើមិនដូច្នោះទេ ត្រូវយកសំពត់កឋិននោះនាំគ្នាទៅរកវត្តណាដែលជិតគួរសម សូមលោកទៅអាវាសវត្តនោះ ហើយសូត្រកម្មវាចាប្រគល់សំពត់កឋិនដល់ភិក្ខុមួយរូបស្រេចហើយ យកសំពត់កឋិននោះមកក្រាលគ្រង អនុមោទនាឯទីដែលចាំវស្សាវិញក៏បាន ។

ជ. ភិក្ខុសាងសាលាបាលី ធ្វើឲ្យត្រូវខ្នាត តែមិនបានឲ្យសង្ឃសំដែងទីឲ្យជាមុនសិន តើនឹងគួរឲ្យលោកត្រូវអាបត្តិតាមសិក្ខាបទទី ៦ ឬទី ៧ នៃសង្ឃាទិសេសដែរឬទេ ?

ឆ. មិនគួរឲ្យលោកត្រូវអាបត្តិទេ គួរតែនាំគ្នាត្រេកអរថែមទៀត ពីព្រោះលោកមានចិត្តស្មោះត្រង់ចំពោះព្រះពុទ្ធសាសនា និងដើម្បីលើកតំកើងព្រះពុទ្ធសាសនាឲ្យមានអាយុយឺនយូរតអង្វែងទៅ ។

ស. បើភិក្ខុឆាន់ត្រីសាចបានហើយ មិនជាហេតុជួយកម្លាំងបាណាតិបាតទៅហើយឬ ? ហេតុអ្វីក៏ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យឆាន់ ? របស់អ្វីខ្លះដែលគួរធ្វើកប្បៈ ហើយត្រូវធ្វើដោយវិធីណាខ្លះ ?

ឆ. មិនមែនជាហេតុជួយកម្លាំងដល់បាណាតិបាតទេ, ព្រោះរបស់ទាំងនោះបរិសុទ្ធដោយហេតុ ៣ យ៉ាងគឺ: មិនឃើញ ១; មិនឮ ១ មិនរង្កៀស ១, ជាគេសម្លាប់បំរុងខ្លួន ។ ហេតុនេះហើយបានជាព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់បានយ៉ាងនេះ ។ របស់ដែលជាពីជគាម ដូចជាផ្លែឈើមានគ្រាប់ដែលអាចបណ្ដុះបានដូចផ្លែព្រីងជាដើម វេលាឆាន់គួរឲ្យអនុបសម្បន្ន (គឺបុគ្គលក្រៅតែភិក្ខុចេញ) ធ្វើកប្បិយសិន ត្រូវចុចនិងក្រចក, ដូច

ប្រើល្អតជាដើម; ត្រូវឲ្យគេចិតក្បាលបន្តិច ៗ សិន, បើគ្រួច
បុសណ្ដែកត្រូវប្រុសសិន សឹមឆាន់ទើបត្រឹមត្រូវតាមព្រះវិន័យ ៗ

( វិញ្ញាសាវិន័យ ប្រឡងយកវិញ្ញាបនប័ត្រ ១៩៦៥ )

១– ភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនា បើត្រូវសឹកទៅជាគ្រហស្ថ តើត្រូវធ្វើដូចម្ដេច? មានពិធីដូចកាលចូលសូមបព្វជ្ជា និងឧបសម្បទាដែរឬដូចម្ដេច? ចូរអធិប្បាយ ៗ

– ភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនានេះ បើត្រូវសឹកទៅជាគ្រហស្ថវិញនោះ ត្រូវប្រកបទៅដោយលក្ខណៈទាំង ៦ យ៉ាងគឺ:

១– ចិត្តចង់សឹកមែន ១, ២. និយាយឲ្យត្រូវខត្តិវត្ថុ ដែលខ្លះត្រូវលះលា ដូចជាព្រះពុទ្ធ ជាដើម, ៣- និយាយឲ្យជាពាក្យបច្ចុប្បន្ន កុំនិយាយជាអតីតកាល និងអនាគតកាល,

៤– បយោគអំពើក្នុងរឿងសឹកនោះ, អំពើមានពីរយ៉ាង;

ក- កាយិកប្បយោគ ខ- វាចិកប្បយោគ ៗ

៥- បុគ្គល: គឺអ្នកណាសឹកនិងអ្នកជាសាក្សី ។

៦- វិធាន: ការដឹងច្បាស់ សំដៅយកបុគ្គលជាសាក្សី ដែលអ្នកសឹកកំណត់យក ១ និងមិនកំណត់ ១ ។ ពុំមានពិធីកម្មដូចកាលចូលសូមបព្វជ្ជា និងឧបសម្បទាទេ ។

អធិប្បាយ : កុលបុត្រដែលមានបំណងនឹងចូលមកសូមបព្វជ្ជានិងឧបសម្បទាក្នុងព្រះពុទ្ធសាសនានេះ ជាដំបូងត្រូវរកបាត្រនិងចីវរឲ្យបានគ្រប់គ្រាន់តាមវិន័យបញ្ញត្តិ ហើយកោរសក់ កោរពុកមាត់ ពុកចង្កា កាត់ក្រចកឲ្យត្រឹមស្មើនឹងសាច់, រួចហើយបព្វជ្ជាបេក្ខៈកាន់គ្រឿងបរិក្ខារនោះ ចូលទៅក្រាបថ្វាយបង្គំទាបបាទាព្រះថេរៈជាអ្នកបំបួស ហើយអង្គុយច្រហោងដាក់បរិក្ខារលើកំភួនដៃប្រណម្យអញ្ជលីសូត្រសូមបព្វជ្ជា តាមបាលីដែលមានក្នុងវិន័យបិដកមហាខន្ធកៈស្រាប់ ។ លុះបព្វជ្ជាចារ្យបានឲ្យបព្វ-ជ្ជារួចហើយ កុលបុត្រត្រូវផ្លាស់សំលៀកបំពាក់គ្រហស្ថៈចោល ហើយស្លៀកស្បង់ត្រងចីពរឲ្យត្រឹមត្រូវតាមវិនយានុរូប, បន្ទាប់

មកត្រូវសុំត្រៃសរណគមន៍ទៀត ទើបបានឡើងជាសាមណេរពេញច្បាប់ ។ ចំណែកសាមណេរដែលមានអាយុពី ២០ ឆ្នាំគត់ឡើងទៅ បើមានបំណងចង់ឧបសម្បទាជាភិក្ខុ ត្រូវចូលទៅសុំឧបសម្បទាអំពីសំណាក់សង្ឃតាំងពី ៥ អង្គឡើងទៅ ។ រីឯការសឹកវិញត្រូវតែសឹកប្រកបដោយលក្ខណៈ តាំង ៦ យ៉ាងដូចបានរៀបរាប់នៅក្នុងចម្លើយខាងលើនេះស្រាប់ ។

២ – ភិក្ខុសាមណេរដែលមិនអាចស្ថិតនៅក្នុងភេទជាភិក្ខុឬសាមណេរក្នុងព្រះពុទ្ធសាសនាតទៅទៀតបាន គឺថាត្រូវតែសឹកទៅគ្រហស្ថ តើមកពីការប្រព្រឹត្តិអំពើដូចម្តេចខ្លះ ? កំហុសនោះមានឈ្មោះដូចម្តេច ? ចូរអធិប្បាយ ។

មកពីការប្រព្រឹត្តិខុសក្នុងព្រះវិន័យ ដែលមិនអាចកែខ្លួនបាន ។ កំហុសនោះឈ្មោះថាបារាជិកធិង នាសនង្គដែលមានទោសធ្ងន់ជាងគេ ។

អធិប្បាយ : បើភិក្ខុសាមណេរ បានប្រព្រឹត្តកន្លងនូវ

សិក្ខាបទធំៗ ដូចបានរៀបរាប់មកខាងលើអម្បាញ់មិញនេះ ត្រូវតែសឹកចាកភេទជាអ្នកបួសទៅជាគ្រហស្ថវិញទើបបាន ។

៣- អាចារ្យ និង ឧបជ្ឈាយ៍ ផ្សេងគ្នាយ៉ាងណា ? បព្វជ្ជាចារ្យ និង ឧបសម្បទាចារ្យផ្សេងពីឧបជ្ឈាយ៍ឬយ៉ាងណា? ចូរពន្យល់ ។

-អាចារ្យ និង ឧបជ្ឈាយ៍ ផ្សេងគ្នាយ៉ាងនេះគឺ៖ អាចារ្យ អ្នកបង្រៀនធម៌វិន័យជាដើម ។ រីឯឧបជ្ឈាយ៍វិញ អ្នករមិលមើលនូវទោសតូច-ធំ នៃសិទ្ធិវិហារិករបស់ខ្លួន ។ បព្វជ្ជាចារ្យ និងឧបសម្បទាចារ្យ ផ្សេងគ្នាយ៉ាងនេះគឺ៖

បព្វជ្ជាចារ្យ បានដល់អ្នកបំបួសសាមណេរ, ឧបសម្បទាចារ្យបានដល់អ្នកឲ្យឧបសម្បទដល់សាមណេរឲ្យឡើងជាភិក្ខុ ។ ឧបជ្ឈាយ៍វិញ គឺជាព្រះថេរៈមួយអង្គដែលចាំតែឃ្លាំមើលទោសតូច និង ទោសធំរបស់ភិក្ខុសាមណេរតែប៉ុណ្ណោះ ។

៤- សិស្សានុសិស្ស ត្រូវបំពេញវត្តប្រតិបត្តិដូចម្តេចខ្លះ ?

ចំពោះឧបជ្ឈាយ៍ និង អាចារ្យ ចូរអធិប្បាយ ។

– សិស្សានុសិស្សត្រូវគោរពប្រតិបត្តិចំពោះឧបជ្ឈាយ៍ និង អាចារ្យដោយសេចក្តីស្មោះត្រង់, យកចិត្តទុកដាក់ស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដោយប្រយ័ត្ន ថែមទាំងមិនត្រូវនិយាយដើមគ្រូ និងយករបស់របរគ្រូដោយគ្មានសេចក្តីអនុញ្ញាតឡើយ ។

= ចប់ =

សូមអានភាគទី ២ តទៅទៀត

តម្កល់ទុកតាម លេខ ១៤២
ចុះថ្ងៃទី ១៦ - ៥ - ៦៩
បោះពុម្ពលើកទី ២ ចំនួន ១៥០០ ក្បាល